**Declassified to Public**
**28 October 2021**



**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ)

ភាគីដាក់ឯកសារ: ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 11-May-2015, 14:49
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សម្ងាត់/Confidential**

ប្រភេទចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ***

---

**<u>ដាក់ដោយ÷</u>**

**សហមេធាវី**

ប៊ិត ស៊ាងលីម

John R.W.D. JONES QC

**<u>ផ្ញើជូន÷</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ÷**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Steven BWANA

**សហព្រះរាជអាជ្ញា÷**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

## I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី (“ក្រុមការពារក្តី”) អនុលោមតាមវិធាន២១ និង វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (“វិធាន” ឬ “វិធានផ្ទៃក្នុង”) តទៅនេះ សូមដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[1] ។

២. នៅក្នុងដីកាសម្រេចដែលរងការជំទាស់ ចៅក្រម Mark B. Harmon មានកំហុសអង្គច្បាប់ដោយប្រព្រឹត្តហួសពីអំណាចដែលគាត់មាន និងបានដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* នៅពេលដែលវិធានផ្ទៃក្នុងតម្រូវឲ្យជនសង្ស័យត្រូវតែមានវត្តមានជាក់ស្តែងក្នុងអំឡុងពេលធ្វើការចោទប្រកាន់ ។ ចៅក្រម Harmon បានផ្អែកលើអ្វីដែលស្តែងឲ្យឃើញថាមាន *ភាពចន្លោះប្រហោង* (*lacunae*) នៅក្នុងវិធានផ្ទៃក្នុង និងច្បាប់នីតិវិធីរបស់កម្ពុជាដើម្បីបញ្ចៀសការប្រើច្បាប់ មានជាធរមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) ។ ជាលទ្ធផល ចៅក្រម Harmon បានបង្កើតនីតិវិធីថ្មី ដោយដាក់ជនសង្ស័យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* តាមរយៈការសម្រាំងជ្រើសយកលក្ខខណ្ឌតម្រូវផ្លូវច្បាប់សម្រាប់កិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ*ជាទូទៅពីតុលាការផ្សេងទៀត មកសំអាងតាមការចង់បានរបស់ខ្លួន ។ ចៅក្រម Harmon ពុំបានបង្ហាញពីសំអាងហេតុនៃការអនុវត្តនូវលក្ខខណ្ឌតម្រូវផ្នែកច្បាប់ទាំងនេះនៅ អ.វ.ត.ក ទេ[2] ។ ហេតុដូច្នេះ ដីកាសម្រេចដែលរងការជំទាស់នេះ រំលោភលើសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានសច្ចភាពផ្នែកច្បាប់ ហើយដីកានេះក៏មានកំហុសផ្នែកច្បាប់ ដែលតម្រូវឲ្យមានការដាក់បណ្តឹងឧទ្ធរណ៍ដើម្បីសុំការអន្តរាគមន៍ ។ ការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺ *ហួសពីអំណាចច្បាប់* (*ultra vires*)។

---

[1] ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D239 (“ដីកាសម្រេចដែលរងការជំទាស់”) ភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់: *ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម* ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D239.1 (“ការជូនដំណឹងអំពីបទចោទប្រកាន់”)។

[2] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៥៨ ។ *សូមមើលផងដែរ* កថាខណ្ឌ៥៩-៦៨ នៃសេចក្តីសម្រេចនេះ។

៣. ក្រុមការពារក្តីសូមស្នើអង្គបុរេជំនុំជម្រះ (ក) ទទួលយកបណ្តឹងឧទ្ធរណ៍នេះ (ខ) ច្រានចោលកថាខណ្ឌ ៣៩, ៤០, ៤២-៤៦, ៥៧-៥៨ និងផ្នែកខ្លះនៃកថាខណ្ឌ៧៣[3] និងកថាខណ្ឌ ៧៦ ដែលទាក់ទងនឹងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម នៅក្នុងការដីកាសម្រេចកំពុងរងការជំទាស់ ដែលជាដីកាមានកំហុសអង្គច្បាប់នេះ និង (គ) ទុកជាមោឃៈនូវសេចក្តីជូនដំណឹងអំពីបទចោទប្រកាន់ ដែល *ហួសពីដែនអំណាចច្បាប់* ។

៤. បច្ចុប្បន្ននេះ បណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី គឺកំពុងស្ថិតក្រោមការពិចារណាដោយអង្គបុរេជំនុំជម្រះថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបង្ហាញ ឬ មិនត្រូវបង្ហាញទេ ពីលក្ខណៈនៃការខ្វែងយោបល់ជាសម្ងាត់ នៅពេលដែលគាត់ធ្វើសកម្មភាពតែម្នាក់ឯងដូច្នេះ[4] ។ ចៅក្រម Harmon បានចេញដីកាសម្រេចដែលរងការជំទាស់នេះដោយឯកតោភាគី ហើយធ្វើការជូនដំណឹងអំពីបទចោទប្រកាន់ដោយផ្អែកលើមូលដ្ឋាននៃការខ្វែងយោបល់ដ៏អាថ៌កំបាំង[5] ។ ក្រុមការពារក្តីរក្សាសិទ្ធិដាក់ទឡ្ហីករណ៍ថ្មី ឬ ទឡ្ហីករណ៍បន្ថែមទាក់ទងនឹងសមត្ថកិច្ចរបស់ចៅក្រម ក្នុងការសម្រេចចោទប្រកាន់អ្នកស្រី អ៊ឹម ចែម ដោយឯកតោភាគី នៅពេលបញ្ហានេះត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ ។

៥. ក្រុមការពារក្តីសូមដាក់ជូនបណ្តឹងឧទ្ធរណ៍នេះ ជាភាសាអង់គ្លេសមុន ហើយអត្ថបទបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយដោយឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ។ ការដាក់ជូនតាមវិធីនេះ ដោយសារមានការអនុញ្ញាតឱ្យដាក់ឯកសារជាបឋមត្រឹមមួយភាសាបាន ចំពោះកាលៈទេសៈពិសេស ដូចបានពន្យល់នៅក្នុងសំណើរបស់ក្រុមការពារក្តី ស្នើសុំដាក់បណ្តឹងឧទ្ធរណ៍

---

[3] ជាពិសេស..."ដោយពិចារណាថា មានភាពមិនច្បាស់លាស់ទាល់តែសោះថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណា ហើយត្រូវអនុវត្ត ឬ អត់នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ការដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស"។

[4] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon លើញត្តិរបស់អ្នកស្រីស្នើសុំឱ្យពិចារណាឡើងវិញ និងមោឃភាពដីកាកោះហៅចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ដាក់នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ លេខឯកសារកំពុងរងចាំការកំណត់។

[5] ដីកាសម្រេចដែលរងការជំទាស់ ត្រង់ទំព័រ១ និងការជូនដំណឹងអំពីបទចោទប្រកាន់ នៅទំព័រ១។

ជាភាសាអង់គ្លេសមុន[6]។

## II. សាវតារ

៦. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតបានចុះបញ្ជី ស្តីពីការខ្វែងយោបល់គ្នា[7] ដែលកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះ ក្រុមការពារក្តីមិនបានដឹងឮឡើយ។

៧. នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ចៅក្រម Harmon បានចេញដីកាកោះហៅអ្នកស្រី អ៊ឹម ចែម ដោយកត់សម្គាល់ពីការ [បានឃើញ] ការខ្វែងយោបល់គ្នា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ នៅក្នុងដីកាកោះរបស់ខ្លួន[8]។ អ្នកស្រី អ៊ឹម ចែម បានបដិសេធមិនចុះហត្ថលេខាលើលិខិតទទួលស្គាល់ការប្រគល់ដីកាកោះ[9]។

៨. នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ អ្នកស្រី អ៊ឹម ចែម មិនបានចូលខ្លួនតាមកាលបរិច្ឆេទកំណត់ឲ្យចូលបង្ហាញខ្លួនជាលើកដំបូងឡើយ[10]។

៩. នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ចៅក្រម Harmon បានចេញដីកាបង្គាប់ឲ្យនាំខ្លួន អ្នកស្រី អ៊ឹម ចែម *(mandat d'amener)* ដើម្បីឲ្យអ្នកស្រីបង្ហាញខ្លួនជាលើកដំបូង[11]។ នៅថ្ងៃទី១៥ ខែសីហា

---

[6] *សូមមើល* សំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ខែមីនា ឆ្នាំ២០១៥ ជាភាសាអង់គ្លេសមុន លេខឯកសារគឺកំពុងរង់ចាំការកំណត់ ។ *សូមមើលផងដែរ* សារអេឡិចត្រូនិកពីលោក KORM Chanmony ទៅកញ្ញា Julianne Romy ក្រោមកម្មវត្ថុ: សំណើជាបន្ទាន់សុំបកប្រែឯកសារ" ធ្វើនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ ។

[7] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ ៣ ។

[8] *ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង* ចុះនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ត្រង់ទំព័រ ២ ឯកសារ A150 ("ដីកាកោះ")។

[9] *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ A150/1 ទំព័រ ២ ។ ដីកាកោះ ទំព័រ ៤ ។

[10] *សូមមើល កំណត់ត្រារបស់ចៅក្រម Harmon* ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ A150/2 ។

[11] *ដីកាបង្គាប់ឲ្យនាំខ្លួន* ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ CI ("ដីកាបង្គាប់ឲ្យនាំខ្លួន") ។ *សូមមើលផងដែរ* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ ២១ ។ ក្រុមមេធាវីការពារក្តីបានដឹងពីការចេញដីកាបង្គាប់ឲ្យនាំខ្លួនអ្នកស្រី អ៊ឹម ចែម តាមរយៈដីកាសម្រេចដែលរងការជំទាស់នេះ ដែលចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ហើយអាចចូលមើលបាននូវច្បាប់ចម្លង

ឆ្នាំ២០១៤ ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានប្រគល់ទៅមន្ត្រីគរបាលយុត្តិធម៌នៃប្រទេសកម្ពុជា ដើម្បីអនុវត្តការនាំខ្លួន[12]។

១០. នៅចន្លោះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ និងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ចៅក្រម Harmon និង តំណាងដទៃទៀតពីការិយាល័យសហចៅក្រមស៊ើបអង្កេត បានរៀបចំកិច្ចប្រជុំមួយចំនួន ជាមួយ តំណាងម្នាក់មកពីនគរបាលយុត្តិធម៌ ទាក់ទងនឹងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន[13]។

១១. នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ចៅក្រម Harmon បានផ្ញើលិខិតមួយច្បាប់ទៅកាន់ប្រធានគណៈ កម្មាធិការសន្តិសុខប្រចាំនៅ អ.វ.ត.ក ទាក់ទងនឹងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលលិខិតនេះ ត្រូវបានទទួលនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៥[14] ។ ចៅក្រម Harmon បានកត់សម្គាល់ថា ប្រសិន បើអ្នកស្រី អ៊ឹម ចែម មិនចូលបង្ហាញខ្លួននៅ អ.វ.ត.ក ឱ្យបានមុនថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ឬ បើអ្នកស្រីមិនត្រូវបានចាប់ខ្លួននៅត្រឹមកាលបរិច្ឆេទនេះទេ នោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងចេញដីកាសម្រេចជាសាធារណៈដាក់ឱ្យអ្នកស្រីស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ*[15] ។

១២. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ចៅក្រម Harmon បានចេញដីកាសម្រេចដែលរងការជំទាស់នេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា "ច្បាប់ដែលអាចអនុវត្តបាន នៅ អ.វ.ត.ក អនុញ្ញាតឱ្យដាក់ជនសង្ស័យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* នៅពេលជនសង្ស័យបដិសេធ មិនចូលបង្ហាញខ្លួនលើកដំបូង ដោយអនុលោមតាមវិធាន៥៧ និងនៅពេលដែលកិច្ចខិតខំប្រឹងប្រែង

---

នៃដីកានេះ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ។ ក្រុមមេធាវីការពារក្តីក៏បានកត់សំគាល់ថា ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានដាក់ ចូលក្នុងសំណុំរឿងនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ។

[12] *លិខិតអមដីកាបង្គាប់ឱ្យនាំខ្លួន* ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ CI.1 ។ *សូមមើលផងដែរ* ដីកាសម្រេចដែលរង ការជំទាស់ នៅកថាខណ្ឌ២១។

[13] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ២៣-២៤, ២៦, ២៨។

[14] *លិខិតដាក់ជូនទៅប្រធានគណៈកម្មាធិការសន្តិសុខប្រចាំនៅ អ.វ.ត.ក* ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ D238 ។ *សូមមើលផងដែរ* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ២៩ ។

[15] *លិខិតដាក់ជូនទៅប្រធានគណៈកម្មាធិការសន្តិសុខប្រចាំនៅ អ.វ.ត.ក* ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ D238 ទំព័រ២។

ជាបន្តបន្ទាប់មកទៀតដើម្បីធានាថា ជនសង្ស័យមានវត្តមានមិនបានទទួលលទ្ធផល"[16] ។ ហេតុដូច្នេះ ចៅក្រម Harmon បានសន្និដ្ឋានថា "លក្ខខណ្ឌតម្រូវផ្លូវច្បាប់ទាំងអស់ដើម្បី ដាក់ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ត្រូវបានបំពេញរួចហើយ[17] ហើយថា ការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* "គឺជាវិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស"[18] ។

## III. ភាពអាចទទួលយកបាន

១៣. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានអនុលោមតាមវិធានពីរ ដូចខាងក្រោម៖

ក. វិធាន២១ ដែលតម្រូវថា ផលប្រយោជន៍របស់ជនសង្ស័យ និង ជនត្រូវចោទ ចាំបាច់ត្រូវតែទទួលបាននូវការការពារគ្រប់ពេលវេលា នៅពេលបកស្រាយបទប្បញ្ញត្តិនានារបស់ អ.វ.ត.ក[19] និង

ខ. វិធាន ៧៤(៣)(ក) ជាវិធានដែលភាគីអាចយោងក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចផ្សេងៗ ដើម្បីបញ្ជាក់ពីភាពទៀតទាត់នៃយុត្តាធិការរបស់ អ.វ.ត.ក[20] ។

<u>វិធាន២១(១)</u>

១៤. បណ្តឹងឧទ្ធរណ៍នេះ អាចទទួលយកបានអនុលោមតាមវិធាន២១(១) នៃវិធានផ្ទៃក្នុង ដែលតម្រូវថា ផលប្រយោជន៍របស់ជនសង្ស័យ និង ជនត្រូវចោទ ចាំបាច់ត្រូវតែទទួលបាននូវការការពារគ្រប់ពេលវេលា នៅពេលបកស្រាយបទប្បញ្ញត្តិនានារបស់ អ.វ.ត.ក ។ អង្គបុរេជំនុំជម្រះធ្លាប់បាន

---

[16] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៥៨។

[17] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៦៨។

[18] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ ៧៣។

[19] វិធានផ្ទៃក្នុង("វិសោធនកម្មលើកទី៩") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ (វិសោធនកម្មធ្វើនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) ("វិធានផ្ទៃក្នុង") វិធាន២១(១) ។

[20] វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ។

សម្រេចថា វិធាន២១ តម្រូវថា "អង្គជំនុំជម្រះត្រូវបកស្រាយឲ្យបានទូលំទូលាយនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្ដឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ និងត្រូវបានការពារក្នុងកាលៈទេសៈនេះ"[21] ។

១៥. ដោយគិតដល់លក្ខណៈពិសេសរបស់តុលាការនេះ ផលប្រយោជន៍របស់ជនសង្ស័យ និងជនត្រូវចោទ ត្រូវតែបានការពារជានិច្ច ដើម្បីធានានូវសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព[22] ។ សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់តម្រូវថា ច្បាប់ត្រូវតែអាចព្យាករបាន និងមានន័យច្បាស់លាស់ ព្រមទាំងមានប្រសិទ្ធិភាពក្នុងការអនុវត្តក្នុងលក្ខណៈមួយដែលអាចទប់ស្កាត់មិនឲ្យមានការធ្វើសេចក្ដីសម្រេចតាមទំនើងចិត្ត[23]។

១៦. ច្បាប់ស្ដីពីនីតិវិធីរបស់ អ.វ.ត.ក ត្រូវតែអនុវត្តដោយអាចព្យាករបាន និង មានភាពច្បាស់លាស់ អនុលោមតាមមាត្រា១២ នៃកិច្ចព្រមព្រៀង[24] ។ ខ្លឹមសារសំខាន់ៗដោយអនុលោមតាមកិច្ចព្រមព្រៀងនេះគឺ ៖ (ក) វិធានផ្ទៃក្នុងមានមូលដ្ឋានគ្រឹះខ្ពស់ជាងគេក្នុងការកំណត់នីតិវិធី[25] (ខ) វិធាននីតិវិធីរបស់ប្រទេសកម្ពុជា អាចអនុវត្តបានលុះត្រាតែមានបញ្ហាចោទណាមួយ ពុំអាចដោះ

---

[21] សំណុំរឿង០០២ *ដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបានបដិសេធមិនទទួលយកការដាក់សារណារបស់លោក អៀង សារី ឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរតាមវិធាន ៦៦ និងការអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា និងសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី* ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 នៅកថាខណ្ឌ ១៣ ។

[22] វិធាន២១ នៃវិធានផ្ទៃក្នុង។

[23] សំណុំរឿងរបស់ D. Soulas de Russel និង P. Raimbault, 'Nature et racines du principe de sécurité juridique : une mise au point' 55 *Revue Internationale de Droit Comparé* 1 (2003) 85-103 ទំព័រ៩៦-៩៧។

[24] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការជំនុំជម្រះក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃ៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង") ។ មាត្រា ១២(១)។

[25] សំណុំរឿង ០០២ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ឯកសារ D55/1/8* ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ("បណ្ដឹងឧទ្ធរណ៍លើសំណើរបស់លោក នួន ជា សុំមោឃភាព") កថាខណ្ឌ ១៤។

ស្រាយបាននៅក្នុងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ[26] និង (គ) ចៅក្រមអាចស្វែងរកការណែនាំឲ្យអនុវត្ត នៅក្នុងវិធាននីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ល្គឹកណាដែលច្បាប់របស់ប្រទេសកម្ពុជាមិនមានចែងពីបញ្ហាចោទណាមួយទាក់ទងនឹងការបកស្រាយច្បាប់ ឬ មានបញ្ហាទាក់ទងទៅនឹងភាពស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ[27] ។ ការស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីអន្តរជាតិ អាចធ្វើបានតែក្នុងករណីចាំចាច់ និងសមស្របតែប៉ុណ្ណោះ[28] ។

១៧. ចៅក្រម Harmon ខកខានមិនបានអនុវត្តច្បាប់ដែលអាចព្យាករបាន និង ច្បាស់លាស់ អនុលោមតាមគោលការណ៍ទាំងនេះ ។ គាត់បានប្រើច្បាប់របស់ប្រទេសកម្ពុជាដោយមិនត្រឹមត្រូវ ខណៈដែលវិធានផ្ទៃក្នុងនៃ អ.វ.ត.ក មិនបង្កឲ្យមាននូវបញ្ហាចោទណាមួយ ដែលពុំអាចដោះស្រាយបានសោះនោះ ហើយជាបន្តបន្ទាប់ គាត់បានស្វែងរកការណែនាំនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិដោយមិនត្រឹមត្រូវ និង មិនចាំបាច់ ព្រោះច្បាប់កម្ពុជាមានចែងយ៉ាងច្បាស់អំពីបញ្ហានេះ ។ ហេតុដូច្នេះ ដីកាសម្រេចដែលរងការជំទាស់នេះគំរាមកំហែងដល់សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ ជាពិសេសចំពោះការដែលចៅក្រម Harmon បានប្រើប្រាស់ខុសនូវកិច្ចដំណើរការនីតិវិធីដែលមានចែងក្នុងមាត្រា១២ ដោយការដណ្តើមយកអំណាចពីអង្គជំនុំជម្រះនៃកិច្ចប្រជុំពេញអង្គរបស់តុលាការ និងបង្កើតនីតិវិធីថ្មី គឺការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ។

១៨. បណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបានយោងលើវិធាន ២១(១) នៃវិធានផ្ទៃក្នុង ពីព្រោះចៅក្រម

---

[26] បណ្តឹងឧទ្ធរណ៍លើសំណើរបស់លោក នួន ជា សុំមោឃភាព នៅកថាខណ្ឌ ១៥ ។ *សូមមើលផងដែរ* សំណុំរឿង០០២ *ដីកាសម្រេចលើសំណើបន្ថែមនៅក្រៅឃុំរបស់លោក ខៀវ សំផន* ឯកសារ C26/5/5 ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ នៅកថាខណ្ឌ ១៧។

[27] កិច្ចព្រមព្រៀង មាត្រា១២(១)។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជំនុំជម្រះលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”) មាត្រា ២៣ថ្មី។

[28] *សូមមើល* សំណុំរឿង០០២ *ដីកាសម្រេចលើអញ្ញត្រកម្មរបស់លោក នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ* ធ្វើនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ៧។

Harmon បានរំលោភសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់ ដែលអត្ថន័យជាក់ស្តែងនៃវិធាន៥៧ ដូចមានពន្យល់នៅខាងក្រោម គឺមិនអនុញ្ញាតឡើយចំពោះការដាក់អ្នកស្រីឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ។ អង្គបុរេជំនុំជម្រះ ត្រូវតែធ្វើការអន្តរាគមន៍ដើម្បីទប់ស្កាត់នូវព្យសនកម្មដែលមិនអាចប៉ះប៉ូវបានមកលើអ្នកស្រី អ៊ឹម ចែម ដែលទទួលរងនូវការចោទប្រកាន់ ដោយសារតែការប្រើច្បាប់មិនអាចយកអនុវត្តបាន និង ក៏មិនមាននៅក្នុងលិខិតុបករណ៍ច្បាប់របស់ អ.វ.ត.ក ឬ ច្បាប់របស់កម្ពុជា[29] ។

<u>វិធាន៧៤(៣)(ក)</u>

១៩. វិធាន៧៤(៣)(ក) ចែងយ៉ាងច្បាស់ថា ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត ដើម្បីពីបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក។ កន្លងទៅ អង្គបុរេជំនុំជម្រះបានសម្រេចថា មានតែការជំទាស់ទៅនឹងបញ្ហាយុត្តាធិការតែប៉ុណ្ណោះ ជាពិសេស យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងបញ្ហាពាក់ព័ន្ធលើកម្មវត្ថុយុត្តាធិការរបស់ អ.វ.ត.ក ទើបអាចនឹងត្រូវបានលើកឡើងនៅក្រោមវិធាននេះ[30] ។

២០. តាមរយៈការចេញដីកាសម្រេចដែលរងការជំទាស់ និង ការចោទប្រកាន់ចំពោះអ្នកស្រី អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ដោយខុសឆ្គងថា គាត់មានយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការតាមកម្មវត្ថុ ក្នុងការសម្រេចលើបញ្ហាជាក់លាក់មកលើរូបអ្នកស្រី ។ ចៅក្រម Harmon គ្មានយុត្តាធិការមកលើអ្នកស្រី អ៊ឹម ចែម នោះទេ ពីព្រោះនីតិវិធី

---

[29] សំណុំរឿង ០០៤ *សម្ភាត់ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣* ធ្វើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ៨។

[30] *សូមមើល* សំណុំរឿង០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)* ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ D97/14/15 នៅកថាខណ្ឌ ២១ ។ *សូមមើល* សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១* ឯកសារ D427/1/30 នៅកថាខណ្ឌ៤៥ និង ៤៧។

នៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដែលគាត់បានបង្កើតឡើងនេះ មិនត្រូវបានអនុញ្ញាតឲ្យអនុវត្តឡើយនៅចំពោះមុខ អ.វ.ត.ក ចំណែកឯការចេញសេចក្តីជូនដំណឹងនៃការចោទប្រកាន់ទៀតសោត គឺ*ហួសពីអំណាចច្បាប់* ដែលគាត់មាន ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះគឺអាចទទួលយកបានស្របតាមវិធាន៧៤(៣)(ក) ។

## IV. ច្បាប់ជាធរមាន

<u>សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌</u>

២១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ប្រទេសកម្ពុជាទទួលស្គាល់ "កតិកាសញ្ញា និង អនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស"[31] ។ មាត្រា១២(២) នៃកិច្ចព្រមព្រៀង និងមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងបន្ថែមថា យុត្តាធិការរបស់ អ.វ.ត.ក ត្រូវតែអនុវត្តឲ្យសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ ។

២២. វិធានផ្ទៃក្នុងចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំឲ្យអនុវត្ត និង បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[32] ។

២៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយចែងថា "ក្នុងការសម្រេចចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ...៖(ក) ត្រូវបានផ្តល់ព័ត៌មានភ្លាមៗ និង ដោយលម្អិតអំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ...និង (ឃ) ត្រូវបានជំនុំជម្រះ

[31] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (អនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣) មាត្រា ៣១។

[32] វិធាន២១(១) នៃវិធានផ្ទៃក្នុង។

ដោយមានវត្តមានរបស់ខ្លួន”[33] ។

<u>ការបកស្រាយច្បាប់ជាធរមាននៅ អ.វ.ត.ក</u>

២៤. អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា (Vienna Convention)[34] អនុវត្តទៅលើកិច្ចព្រមព្រៀង[35] ។ កិច្ចព្រមព្រៀងក៏ចែងផងដែរថា “នៅពេលដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬ មានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬ ក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះជាមួយនឹងបទដ្ឋានអន្តរជាតិ នោះតុលាការអាចស្វែងរកការណែនាំពីបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”[36]។

២៥. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេត “ត្រូវអនុវត្តនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ”[37] ។

២៦. វិធានផ្ទៃក្នុងចែងថា “នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ...សហចៅក្រមស៊ើបអង្កេត...

---

[33] មាត្រា១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦) 999UNTS 171 (“ICCPR”) ។ អ.វ.ត.ក ត្រូវតែអនុវត្តយុត្តាធិការឲ្យស្របតាមមាត្រា ១៤ នៃកតិកាសញ្ញា ICCPR។ *សូមមើល* កិច្ចព្រមព្រៀង មាត្រា ១២(២)។

[34] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា (អនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ ហើយចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០) ឯកសារលេខ 1155 UNTS 331 (1969) (“អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា”) ។

[35] កិច្ចព្រមព្រមព្រៀង មាត្រា២(២)។

[36] កិច្ចព្រមព្រមព្រៀង មាត្រា១២(១)។

[37] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា២៣ថ្មី។

ត្រូវធ្វើការសម្រេចចិត្តដោយស្របទៅលើមាត្រា១២(១) នៃកិច្ចព្រមព្រៀង និង មាត្រា ២០ថ្មី មាត្រា ២៣ថ្មី មាត្រា ៣៣ថ្មី ឬ មាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងនេះ ព្រមទាំងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន ។ ក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ត្រូវដាក់ជូនទៅគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន[38] ។ បន្ថែមពីលើនេះ វិធាន៣ អភិបាលលើនីតិវិធីធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនៅ អ.វ.ត.ក និង បានចែងថា សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងដែលបញ្ជូនពីគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង ត្រូវដាក់ជូនកិច្ចប្រជុំពេញអង្គដើម្បីអនុម័ត[39] ។

<u>នីតិវិធីសម្រាប់ធ្វើការចោទប្រកាន់នៅ អ.វ.ត.ក</u>

២៧. វិធានផ្ទៃក្នុងចែងថា "នៅពេលជនត្រូវចោទចូលបង្ហាញខ្លួនចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ[40] ។ ជនត្រូវចោទមានសិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលដែលខ្លួនត្រូវបានសួរចម្លើយ និងមានមេធាវីអមជាមួយនៅក្នុងពេលសួរចម្លើយ ។ ប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយ នោះសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការសួរចម្លើយនោះភ្លាម[41] ។

២៨. "ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ"[42] ។ វិធានផ្ទៃក្នុងចែងបន្ថែមទៀតថា "នៅពេលដែលជនជាប់ចោទបដិសេធមិនចូលរួមក្នុងនីតិវិធី ជនជាប់ចោទនឹងត្រូវនាំខ្លួន

---

[38] វិធាន២ នៃវិធានផ្ទៃក្នុង ។

[39] វិធាន៣(១) និង៣(២) នៃវិធានផ្ទៃក្នុង ។ *សូមមើលផងដែរ* វិធាន ១៨ និង វិធាន ២០ នៃវិធានផ្ទៃក្នុង ។

[40] វិធាន៥៧(១) នៃវិធានផ្ទៃក្នុង ។

[41] វិធាន៥៧(១) នៃវិធានផ្ទៃក្នុង ។

[42] វិធាន៨១(១) នៃវិធានផ្ទៃក្នុង ។

មកកាន់អង្គជំនុំជម្រះសាលាដំបូងដោយកំលាំងសាធារណៈប្រសិនបើចាំបាច់ នៅពេលនោះ ជនជាប់ចោទ ត្រូវតែបានជូនដំណឹងអំពីសិទ្ធិដែលត្រូវមានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន...”[43] និង “ក្រោយពេលបង្ហាញខ្លួនជាលើកដំបូង និង បានទទួលដីកាកោះដោយត្រឹមត្រូវសម្រាប់ចូលរួមក្នុងសវនាការជាបន្តបន្ទាប់ ប្រសិនបើជនជាប់ចោទនៅតែបន្តបដិសេធ ឬ ខកខានមិនបានចូលរួម...កិច្ចដំណើរការនីតិវិធីអាចបន្តទៅបាន ដោយអវត្តមានរបស់ជនជាប់ចោទរូបនោះ”[44] ។

## V. បទដ្ឋាននៃការត្រួតពិនិត្យ

២៩. “ការដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអាចត្រូវបានច្រានចោល ប្រសិនបើដីកាសម្រេចនោះ(ក) បានផ្អែកលើមូលដ្ឋានអង្គច្បាប់មានកំហុស ដែលធ្វើឲ្យដីកាសម្រេចនេះគ្មានសុពលភាព (ខ) ដីកាដែលបានផ្អែកលើមូលដ្ឋានអង្គហេតុមានកំហុស ផ្តល់ឱកាសឲ្យមានភាពបរាជ័យក្នុងកិច្ចដំណើរការស្វែងរកយុត្តិធម៌ ឬ (គ) គ្មានភាពយុត្តិធម៌ ឬ មិនសមហេតុផល ដែលនាំឲ្យមានការរំលោភបំពាននូវឆន្ទានុសិទ្ធិរបស់ចៅក្រម[45] ។

## VI. អំណះអំណាង

### ទឡ្ហីករណ៍សង្ខេប

៣០. វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា ជនសង្ស័យត្រូវចូលបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងពេលធ្វើការចោទប្រកាន់ ។ ភាពច្បាស់លាស់នៃវិធានផ្ទៃក្នុង មាន

---

[43] វិធាន៨១(៣) នៃវិធានផ្ទៃក្នុង ។

[44] វិធាន៨១(៤) នៃវិធានផ្ទៃក្នុង ។

[45] សំណុំរឿង ០០២ *សាធារណៈ កោសលុប សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំអនុញ្ញាតឲ្យថតយកសម្លេង/រូបភាព ឬជួបជាមួយអៀង សារី នៅមន្ទីរឃុំឃាំង* ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ A317/2/12 កថាខណ្ឌ ២២។

ន័យថា ចៅក្រម Harmon មិនអាចសម្រេចទៅប្រើច្បាប់កម្ពុជាដើម្បីកំណត់ថាតើគាត់អាចដាក់ឲ្យជនសង្ស័យឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* បាន ឬ អត់ នោះទេ ។ ទោះក្នុងករណីណាក៏ដោយ ច្បាប់កម្ពុជាក៏តម្រូវឲ្យជនសង្ស័យចូលបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខចៅក្រមស៊ើបសួរក្នុងពេលត្រូវធ្វើការចោទប្រកាន់លើរូបគាត់ ។ ពុំមានឡើយនូវភាពមិនច្បាស់លាស់ ឬមានបញ្ហាចោទណាមួយទាក់ទងនឹងភាពសមស្របគ្នា នៃវិធានច្បាប់របស់កម្ពុជាជាមួយនឹងបទដ្ឋានអន្តរជាតិ ដែលអនុញ្ញាតឲ្យចៅក្រម Harmon ស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីព្រហ្មទណ្ឌអន្តរជាតិនោះទេ ។ ម្យ៉ាងវិញទៀត វិធាននីតិវិធីព្រហ្មទណ្ឌអន្តរជាតិគ្មានការណែនាំស្តីពីការដាក់ជនសង្ស័យឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* នោះដែរ ហើយចៅក្រម Harmon ផ្ទាល់ ខកខានមិនបានផ្តល់យុត្តិកម្មថា មូលហេតុអ្វីទើបគាត់អាចនាំយកវិធានទាំងនេះមកប្រើនៅ អ.វ.ត.ក ។ ជាចុងក្រោយ ចៅក្រម Harmon បានប្រព្រឹត្តហួសពីអំណាចដែលខ្លួនមាន និងបានដើរតួជំនួសឲ្យអង្គជំនុំជម្រះនៃកិច្ចប្រជុំពេញអង្គ ក្នុងការបង្កើតនីតិវិធីថ្មីដោយដាក់ជនសង្ស័យឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដែលនីតិវិធីនេះ រំលោភលើសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ចំពោះការទទួលបានសច្ចភាពផ្លូវច្បាប់ ។ ហេតុដូច្នេះ ការលើកឡើងរបស់ចៅក្រម Harmon ដែលថា ច្បាប់ជាធរមាននៅ អ.វ.ត.ក អនុញ្ញាតឲ្យគាត់អាចដាក់ជនសង្ស័យឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជាកំហុសផ្លូវច្បាប់មួយ ហើយការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ នេះ* គឺ *ហួសពីដែនអំណាច* ។

### ភ. វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ មិនអនុញ្ញាតឲ្យអនុវត្តចំពោះការដាក់ជនសង្ស័យឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ទេ

៣១. វិធានផ្ទៃក្នុង "គឺជាលិខិតុបករណ៍ចម្បងដែលត្រូវបានយកប្រើប្រាស់ក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក"[46] ។ ដំណើរការចោទប្រកាន់នៅ អ.វ.ត.ក ដូចដែលមានចែងនៅក្នុងវិធាន៥៧ គឺច្បាស់លាស់ ដែលមានខ្លឹមសារដូច្នេះថា: វិធានផ្ទៃក្នុងតម្រូវឲ្យជនសង្ស័យត្រូវចូលបង្ហាញខ្លួន

[46] បណ្តឹងឧទ្ធរណ៍លើសំណើរបស់លោក នួន ជា សុំមោឃភាព កថាខណ្ឌ ១៤។

នៅក្នុងពេលធ្វើការចោទប្រកាន់ ។ ហេតុដូច្នេះ ចៅក្រម Harmon មានកំហុសអង្គច្បាប់នៅក្នុងការសន្និដ្ឋានថា ការចូលបង្ហាញខ្លួនដោយផ្ទាល់របស់ជនសង្ស័យ គឺមិនមែនជាលក្ខខណ្ឌចាំបាច់[47] ។

**ក. វិធាន៥៧៖ ការចូលបង្ហាញខ្លួនរបស់ជនសង្ស័យ គឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់សហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម[48]**

៣២. តុលាការព្រហ្មទណ្ឌអន្តរជាតិ មានមូលដ្ឋានគ្រប់គ្រាន់ឱ្យអនុវត្តដើម្បីធ្វើការបកស្រាយវិធាននីតិវិធីរបស់ពួកគេ ដោយអនុលោមតាមមាត្រា៣១ និង មាត្រា៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា[49] ។ វិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និង តុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (ICTR) ត្រូវបានបកស្រាយតាមវិធីនេះ ពីព្រោះនីតិវិធីទាំងនោះ កើតចេញពីលក្ខន្តិកៈរបស់តុលាការ ICTY ឬ តុលាការ ICTR ដែលត្រូវបានផ្តល់សុពលភាពដោយអនុសញ្ញាអន្តរជាតិ[50]។ កាន់តែខ្លាំងទៅជាងនេះ គឺថាអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានបញ្ជាក់ថា បទប្បញ្ញត្តិបកស្រាយរបស់អនុសញ្ញាទីក្រុង

---

[47] *សូមមើល* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤០។

[48] មានភាពផ្ទុយគ្នាទាក់ទងនឹងការសំអាងហេតុរបស់ចៅក្រម Harmon ។ *សូមមើល* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ ៤០។

[49] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Slobodan Milošević* (IT-02-54-A) *សំអាងហេតុសម្រាប់សាលដីកាលើបណ្តឹងបន្ទាន់របស់រដ្ឋអាជ្ញាពីការបដិសេធមិនបង្គាប់ឱ្យមានបណ្តឹងរួម* ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ កថាខណ្ឌ ១៦។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jelisić* (IT-95-10-A) *សាលក្រម* ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ ៣៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Erdemović (IT-96-22-A) *សាលក្រម* ទស្សនៈផ្ទុយរួមគ្នារបស់ចៅក្រម McDonald និងចៅក្រម Vohrah ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៧ ត្រង់កថាខណ្ឌ៣ ។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Joseph Kanyabashi* (ICTR-96-15-A) *សាលដីកា លើញត្តិរបស់ក្រុមមេធាវីការពារក្តីសុំបណ្តឹងឧទ្ធរណ៍បន្ទាន់លើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង I* (*សាលដីកាលើបណ្តឹងឧទ្ធរណ៍*) ទស្សនៈផ្ទុយគ្នា និងស្របរួមគ្នារបស់ចៅក្រម Wang និងចៅក្រម Nieto-Navia ថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៩៩ នៅកថាខណ្ឌ ១១។

[50] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Joseph Kanyabashi* (ICTR-96-15-A) *សាលដីកាសម្រេចលើញត្តិរបស់មេធាវីការពារក្តីចំពោះដែនសមត្ថកិច្ចយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង I ក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍* (*សាលដីកាលើបណ្តឹងឧទ្ធរណ៍*), សាលដីកាដែលរួមបញ្ចូលនូវទស្សនៈស្របគ្នា និង ទស្សនៈផ្ទុយគ្នារបស់ចៅក្រម Wang និងចៅក្រម Nieto-Navia ថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៩៩ នៅកថាខណ្ឌ ១១។

វីយែន ស្តីពីច្បាប់សន្ធិសញ្ញាត្រូវផ្ទុះបញ្ចាំងច្បាប់ទម្លាប់អន្តរជាតិ[51] ។

៣៣. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ត្រូវតែបកស្រាយអនុលោមតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ពីព្រោះវិធានផ្ទៃក្នុងនេះ ក៏មានប្រភពមកពីសន្ធិសញ្ញាមួយដែរ ដែលមានឈ្មោះថា កិច្ចព្រមព្រៀង[52] ។ ហេតុដូច្នេះ អនុលោមតាមមាត្រា៣១ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា វិធានផ្ទៃក្នុងត្រូវតែបានបកស្រាយក្នុងភាពសុច្ចរិតសមស្របតាមន័យធម្មតានិង នៅក្នុងបរិបទរបស់វា និងដោយផ្អែកតាមគោលដៅ និងវត្ថុបំណងរបស់ខ្លួន[53] ។

៣៤. អត្ថន័យធម្មតាដោយសុទ្ធចិត្តនៃវិធាន៥៧ តម្រូវថា វត្តមានជាក់ស្តែងរបស់អ្នកស្រី អ៊ឹម ចែម ក្នុងពេលចូលបង្ហាញខ្លួនលើកដំបូង គឺជាបុរេលក្ខខណ្ឌដើម្បីឱ្យចៅក្រម Harmon ធ្វើការចោទប្រកាន់លើរូបអ្នកស្រីបាន ។ តុលាការអាចធ្វើការចោទប្រកាន់លើជនសង្ស័យបានតែ "នៅពេលចូលបង្ហាញខ្លួនលើកដំបូង"[54] តែប៉ុណ្ណោះ ដែលការចូលបង្ហាញខ្លួននេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង ថាជាការ "សំដៅទៅលើការបង្ហាញខ្លួនលើកដំបូងរបស់ជនត្រូវចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត"[55] ។

៣៥. អត្ថន័យធម្មតានៃពាក្យ *ការបង្ហាញខ្លួន* (appear) គឺមានន័យថា ត្រូវតែមានវត្តមានជាក់ស្តែងរបស់

---

[51] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* (IT-96-21-A) *សាលក្រម* ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ នៅកថាខណ្ឌ ៦៧ *ដោយដកស្រង់រឿងក្តីទាក់ទងនឹងជម្លោះដែនដី រវាងប្រទេស (លីប៊ី អារ៉ាប់ ចាម៉ាហ៊ីរីយ៉ា/ឆាដ) សាលក្រមឆ្នាំ (១៩៩៤)* របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ (I.C.J.) ទំព័រ ២១ នៅកថាខណ្ឌ ៤១ អនុម័តនៅក្នុង*រឿងក្តីទាក់ទងនឹងការកំណត់ព្រំដែនដែនទឹក និងបញ្ហាដែនដីរវាងប្រទេស កាតា និងបារ៉ែន* (យុត្តាធិការ និងភាពអាចទទួលយក*) សាលក្រម* (ឆ្នាំ ១៩៩៥) របាយការណ៍ I.C.J. ទំព័រ ១៨ នៅកថាខណ្ឌ ៣៣។ *សូមមើលផងដែរ* រឿងក្តី *Kasikili/Sedudu Island* (បុតស្វាណា/ណាមីប៊ី) *សាលក្រម* (ឆ្នាំ ១៩៩៩) របាយការណ៍របស់តុលាការ I.C.J ទំព័រ ១០៥៩ នៅកថាខណ្ឌ ១៨។

[52] កិច្ចព្រមព្រៀង មាត្រា២(២)។

[53] មាត្រា៣១(១) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា។

[54] វិធាន៥៧(១) នៃវិធានផ្ទៃក្នុង ។ ក្រុមមេធាវីការពារកត់សម្គាល់ថា វិធាន៥៧ នៃវិធានផ្ទៃក្នុង គឺផ្តល់អំណាចចំណាត់ការ នៃ "ការជូនដំណឹងអំពីបទចោទប្រកាន់"។

[55] *សូមមើល* សទ្ទានុក្រមនៃវិធានផ្ទៃក្នុង ទំព័រ៨៤។

ជនណាម្នាក់ ។ នៅក្នុងវចនានុក្រមនានា សុទ្ធតែកំណត់និយមន័យនៃពាក្យ *បង្ហាញខ្លួន* (appear) ស្រដៀងគ្នានឹងពាក្យមួយចំនួនទៀត ដូចជា៖“មានវត្តមាន (to be present)”[56] ការ “បង្ហាញខ្លួន (to show up)”[57] ការ “ចូលរួម ឬ មានវត្តមាន (attend or be present)”[58] ឬការ “មកឱ្យឃើញ (to come into sight or view)”[59] ។ ការបញ្ជាក់កាន់តែច្បាស់ជាងនេះ គឺថា ការបកប្រែនេះ ត្រូវបានគាំទ្រដោយនិយមន័យច្បាប់នៃពាក្យ *បង្ហាញខ្លួន (appear)* និង*ការចូលបង្ហាញខ្លួន (appearance)* ដោយរួមបញ្ចូលទាំងការ *“មានវត្តមាននៅក្នុងតុលាការ (to be present in court)”*[60] “ការចូលខ្លួននៅតុលាការ (*coming into court*)”[61] “ឈរនៅចំពោះមុខអាជ្ញាធរ ឬ តុលាការ (*to stand in the presence of some authortity, tribunal*)”[62] “បង្ហាញខ្លួនជាផ្លូវការនៅក្នុងតុលាការ (*present oneself formally in court*)”[63] ឬ “ចូលខ្លួនជាផ្លូវការនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច (*to come formally before an authoritative body*)”[64] ។ ចំពោះពាក្យថា *បង្ហាញខ្លួន (toappear)* ឬ *បង្ហាញខ្លួននៅចំពោះមុខចៅក្រម (toappear before a judge)* គឺគ្មាននិយមន័យណាដែលមានន័យធម្មតាដោយសុទ្ធចិត្តដែលសំដៅថា មិនចាំបាច់ឱ្យមានវត្តមានជាក់ស្តែង

[56] វចនានុក្រម Cambridge Dictionaries Online, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://dictionary.cambridge.org/dictionary/british/appear

[57] វចនានុក្រម Merriam-Webster, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.merriam-webster.com/dictionary/appear

[58] វចនានុក្រម Dictionary.com, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://dictionary.reference.com/browse/appear

[59] វចនានុក្រម Collins, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.collinsdictionary.com/dictionary/english/appear?showCookiePolicy=true

[60] វចនានុក្រម Collins, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.collinsdictionary.com/dictionary/english/appear?showCookiePolicy=true

[61] វចនានុក្រមរៀបរៀងដោយ Garner និងអ្នកផ្សេងទៀត, Black’s Law Dictionary (WEST, Ninth ed., 2009) (និយមន័យនៃពាក្យចូលបង្ហាញខ្លួន)” ។

[62] វចនានុក្រម Merriam-Webster, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.merriam-webster.com/dictionary/appear

[63] វចនានុក្រមមួយចំនួននៃសាកលវិទ្យាល័យ Oxford, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.oxforddictionaries.com/definition/english/appear.

[64] វចនានុក្រម Merriam-Webster, ពាក្យ “appear”, ចូលមើលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅ: http://www.merriam-webster.com/dictionary/appear

របស់បុគ្គលណាម្នាក់នោះឡើយ ។

៣៦. អត្ថន័យធម្មតានៃកិច្ចដំណើរការនីតិវិធីរបស់វិធាន៥៧ ក៏តម្រូវឱ្យអ្នកស្រី អ៊ឹម ចែម ត្រូវមានវត្តមានជាក់ស្តែងក្នុងអំឡុងពេលចោទប្រកាន់លើរូបអ្នកស្រី តាមរយៈការចែងដូច្នេះថា សហចៅក្រមស៊ើបអង្កេតត្រូវ "កត់ត្រាអត្តសញ្ញាណរបស់ជនត្រូវចោទ"[65] នៅពេលមានការចូលបង្ហាញខ្លួនលើកដំបូង ហើយប្រសិនបើជនត្រូវចោទយល់ព្រមឆ្លើយ នោះសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការសួរចម្លើយនោះ "ភ្លាម"[66] ។ ជាពិសេស ចៅក្រម Harmon បានបញ្ជាក់ថា ជនសង្ស័យមានសិទ្ធិធ្វើសេចក្តីថ្លែងការណ៍ក្នុងអំឡុងពេលនៃការចូលបង្ហាញខ្លួនលើកដំបូង[67] ។ ទាំងនេះ មិនអាចប្រព្រឹត្តទៅបានដោយគ្មានវត្តមានរបស់ជនសង្ស័យបានឡើយ ។ សហចៅក្រមស៊ើបអង្កេតបានអនុវត្តតាមនីតិវិធីទាំងនេះ ដោយអនុលោមតាមអត្ថន័យធម្មតានៅពេលធ្វើការចោទប្រកាន់លើលោក កាំង ហ្គេចអ៊ាវ ហៅ "ឌុច" លោក នួន ជា លោក អៀង សារី និង លោក អោ អាន[68] ។

---

[65] វិធាន៥៧(១) នៃវិធានផ្ទៃក្នុង។

[66] វិធាន៥៧(១) នៃវិធានផ្ទៃក្នុង។

[67] *សូមមើល កំណត់ហេតុនៃការចូលបង្ហាញខ្លួនលើកដំបូង* របស់លោក អោ អាន (ជាភាសាខ្មែរ) ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ទំព័រទី៨ ។

[68] *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង*របស់ជនសង្ស័យទាំងបីរូបនៃសំណុំរឿង០០១ និង ០០២ លើកឡើងយ៉ាងច្បាស់ដូចខាងក្រោម៖ "បានចូលខ្លួននៅចំពោះមុខយើង និងបានផ្តល់ព័ត៌មានស្តីពីអត្តសញ្ញាណដូចខាងក្រោម" បន្ទាប់មកជនសង្ស័យបានបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន។ *សូមមើល កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក ឌុច* ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ E3/915 ទំព័រ១-២ *កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក នួន ជា* ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ E3/54 ទំព័រ ១-២ *កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក អៀង សារី* ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/92 ទំព័រ ១-២។ លោក អោ អាន ក៏ត្រូវបានស្នើសុំឱ្យបញ្ជាក់ពីអត្តសញ្ញាណរបស់គាត់ដែរ ។ *សូមមើល*កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការចូលបង្ហាញខ្លួនដំបូងរបស់លោក អោ អាន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D242 ។ បន្ថែមពីលើនេះទៀត *កំណត់ហេតុនៃការចូលខ្លួនដំបូង* របស់ជនសង្ស័យទាំងបួនរូប បង្ហាញថា ជនសង្ស័យត្រូវបានផ្តល់ឱកាសឱ្យធ្វើការកត់សម្គាល់បន្ទាប់ត្រូវបានជូនដំណឹងអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ និងពិគ្រោះយោបល់ជាមួយមេធាវីមុននឹងពួកគាត់ត្រូវបានសួរចម្លើយ ។ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងទាំងបួននេះ បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើជនសង្ស័យមានបំណងធ្វើការកត់សម្គាល់ សហចៅក្រមស៊ើបអង្កេតនឹងកត់ត្រាការកត់សម្គាល់នោះភ្លាម។ *សូមមើល កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក ឌុច* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ E3/915 ទំព័រ៣ *កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក នួន ជា* ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54 ទំព័រ៤ *កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក អៀង សារី*

បុគ្គលទាំងអស់នេះ សុទ្ធតែមានវត្តមានជាក់ស្តែងដូចដែលតម្រូវដោយវិធាន៥៧ ។ ដោយការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចៅក្រម Harmon ខកខានមិនបានធ្វើការកត់ត្រានូវអត្តសញ្ញាណរបស់អ្នកស្រី និង មិនអាចសួរចម្លើយគាត់បានភ្លាមៗនោះដែរ។

៣៧. ជាចុងក្រោយ វិធាន ៥៧(៣) តម្រូវឲ្យជនត្រូវចោទត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអំពីអាសយដ្ឋានរបស់ខ្លួន ប្រសិនបើគាត់ "មិនត្រូវបានឃុំខ្លួនក្រោយពេលចូលបង្ហាញខ្លួនលើកដំបូង" ទេនោះ ។ ការព្យាករពីការដោះលែងបន្ទាប់ពីបានចូលបង្ហាញ ខ្លួនលើកដំបូងនៃវិធាននេះគឺគ្មានន័យឡើយ លុះណាតែជននោះមានវត្តមានជាក់ស្តែងសិន ទើបមានការដោះលែងទៅកើត ។

៣៨. ហេតុដូច្នេះ ចៅក្រម Harmon មានកំហុសនៅក្នុងការសម្រេចដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ខណៈដែលអត្ថន័យធម្មតានៃវិធាន៥៧ តម្រូវឲ្យអ្នកស្រីត្រូវមានវត្តមានក្នុងពេលត្រូវធ្វើការចោទប្រកាន់[69] ។

## ខ. អ្នករៀបចំសេចក្តីព្រាងវិធានផ្ទៃក្នុង មិនមានបំណងឲ្យមានករណីលើកលែងចំពោះលក្ខខណ្ឌតម្រូវដែលថា ជនសង្ស័យត្រូវតែចូលបង្ហាញខ្លួនលើកដំបូងឡើយ

៣៩. តាមការពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយក្រោយពីការអានទាំងស្រុងនូវវិធានផ្ទៃក្នុងដែលបានចែងច្បាស់ណាស់ថា អ្នកពង្រាងមានចេតនាឲ្យជនសង្ស័យត្រូវតែមានវត្តមាននៅពេលចូលបង្ហាញខ្លួនជាលើកដំបូងដោយគ្មានករណីលើកលែងឡើយ[70] ។ បទប្បញ្ញត្តិទាំងឡាយណាដែលចែងពីករណី

---

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/92 ទំព័រ ៣-៤។ គួរកត់សម្គាល់ថា ក្រុមការពារក្តីមិនអាចចូលពិនិត្យមើល *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* របស់លោក ខៀវ សំផន និងអ្នកស្រី អៀង ធីរិទ្ធ បានទេ ។

[69] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤០។

[70] អត្ថន័យក្នុងបទប្បញ្ញត្តិនេះត្រូវតែបានបកស្រាយដោយពិចារណាលើការបកស្រាយ និងបរិបទនៃលិខិតុករណ៍ច្បាប់នេះទាំងមូល។ *សូមមើល* សំណុំរឿង *រដ្ឋអាជ្ញា តទល់ Dusko Tadić* (IT-94-1-AR72), ដីកាសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំលើយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ នៅកថាខណ្ឌ៩០។

លើកលែងមួយចំនួនចំពោះវិធានទូទៅណាមួយ ចាំបាច់ត្រូវតែបកស្រាយក្នុងកម្រិតតឹងរ៉ឹង[71] ។ អ្នកពង្រាងវិធានផ្ទៃក្នុង គួរតែអាចសន្មតបានពីការប្រព្រឹត្តដោយចេតនា និងបំណងប្រាថ្នា នៅពេលពួកគេបញ្ចូលនូវករណីលើកលែងណាមួយទៅក្នុងផ្នែកមួយ តែត្រូវលុបវាវិញនៅផ្នែកមួយទៀត ។ ហេតុដូច្នេះ នៅពេលអ្នកពង្រាងវិធានផ្ទៃក្នុងដាក់លក្ខខណ្ឌកម្រិតមួយចំនួននៅក្រោមវិធាន៨១ ដែលតម្រូវឲ្យមានវត្តមាននៅពេលជំនុំជម្រះ ពួកគេដាក់លក្ខខណ្ឌនេះ ដោយមានចេតនាចំពោះការមិនផ្តល់នូវលក្ខខណ្ឌដាក់កម្រិតស្រដៀងគ្នាណាមួយនៃសេចក្តីតម្រូវឲ្យមានវត្តមាននៅក្រោមវិធាន៥៧ សម្រាប់ធ្វើការចោទប្រកាន់នោះឡើយ ។

៤០. នៅក្នុងបរិបទនៃការពិភាក្សាលើករណីលើកលែង ដែលអនុញ្ញាតឲ្យមានកិច្ចដំណើរការនីតិវិធីបន្តទៅបានដោយគ្មានវត្តមានរបស់ជនសង្ស័យ វិធាន៨១(៤) គាំទ្រការបកស្រាយនេះដោយបានបញ្ជាក់ឡើងវិញថា ការចូលបង្ហាញខ្លួនលើកដំបូង[72] ជានិច្ចជាកាលត្រូវតែកើតមានជាកំហិត ។ បទប្បញ្ញត្តិនេះចែងថា សវនាការអាចបន្តកិច្ចដំណើរការ*ដោយកំបាំងមុខ* បានតាមលក្ខខណ្ឌមួយចំនួន ដរាបណាជនជាប់ចោទបាន “ចូលបង្ហាញខ្លួនជាលើកដំបូង និង បានទទួលដីកាកោះដោយត្រឹមត្រូវសម្រាប់ចូលរួមក្នុងកិច្ចសវនាការជាបន្តបន្ទាប់”[73] ។

៤១. ចេតនានេះ មិនអនុញ្ញាតឲ្យមានការលើកលែងឡើយចំពោះការចូលបង្ហាញខ្លួនលើកដំបូង បើតាមការស្តែងឲ្យឃើញនៅពេលពិនិត្យលើកិច្ចពិភាក្សាដើម្បីរៀបចំតាក់តែងវិធានផ្ទៃក្នុង ។ ឯកសារកើតចេញពីការពិភាក្សានេះ គឺជាគោលការណ៍មូលដ្ឋានគ្រឹះមួយ សម្រាប់ធ្វើការបកស្រាយច្បាប់

---

[71] *សូមមើល* ឧទាហរណ៍នៃសំណុំរឿង *Witold Litwa* ទល់នឹងប្រទេស *Poland* (សំណើលេខ 26629/95), តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR), ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០០ នៅកថាខណ្ឌ៥៩ ។ ក្រិត្យស្តីពីសញ្ជាតិ ចេញនៅទីក្រុងទុយនីស (*Tunis*) និង នៅទីក្រុងម៉ារ៉ុក (*Morocco*) (មតិយោបល់ពីក្រុមប្រឹក្សាភិបាល), តុលាការអចិន្ត្រៃយ៍ស្តីពីយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩២៣ ទំព័រ២៥ ។

[72] ក្រុមការពារក្តីកត់សម្គាល់ថា ចៅក្រម Harmon បានយោងដោយមិនត្រឹមត្រូវនៅក្នុងដីកាសម្រេចដែលរងការជំទាស់ថាការចូលបង្ហាញខ្លួនលើកដំបូងនៅក្នុងវិធាន៨១(៤) ថាជា “សវនាការបឋម” ។ *សូមមើល* ដីកាសម្រេចដែលការជំទាស់នៅកថាខណ្ឌ៣៩ ។

[73] វិធាន៨១(៤) នៃវិធានផ្ទៃក្នុង ។

ស្របតាមមាត្រា៣២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ។ មាត្រានេះ អនុញ្ញាតឱ្យប្រើ "មធ្យោបាយបកស្រាយបន្ថែម ដោយរាប់បញ្ចូលទាំងកិច្ចការរៀបចំសន្ធិសញ្ញា និង កាលៈទេសៈនៃការបញ្ចប់ការងារនេះ ដើម្បីបញ្ជាក់ពីអត្ថន័យដែលកើតចេញពីការអនុវត្តមាត្រា ៣១" នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា ។ ក្នុងអំឡុងពេលធ្វើការពង្រាងវិធានផ្ទៃក្នុង អង្គជំនុំជម្រះនៃកិច្ចប្រជុំពេញអង្គ បានពិភាក្សាថាតើកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតឱ្យដាក់ក្នុងវិធានផ្ទៃក្នុង ដែរ ឬ យ៉ាងណា ហើយកិច្ចប្រជុំបានឯកភាពថា កិច្ចដំណើរការជំនុំជម្រះ អាចបន្តបានដោយអវត្តមានជនជាប់ចោទ "ឱ្យតែគាត់បានចូលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខ អ.វ.ត.ក"[74] ។

៤២. ទីបំផុត ការបកស្រាយនេះក៏ត្រូវបានគាំទ្រដោយការអនុវត្តជាក់ស្តែង និង តាមរយៈករណីយុត្តិសាស្ត្រនៅ អ.វ.ត.ក ផងដែរ ។ ដូចដែលបានលើកឡើងពីខាងលើកំណត់ហេតុរបស់ អ.វ.ត.ក បង្ហាញថា ដំណើរការចោទប្រកាន់លើលោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច" លោក នួន ជា លោក អៀង សារី និងលោក អោ អាន កើតឡើងនៅពេលពួកគាត់ចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[75] ។

---

[74] 'បច្ចុប្បន្នភាពស្តីពី អ.វ.ត.ក លោក David Scheffer នឹងមកកម្ពុជា' Wikileaks ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ នៅកថាខណ្ឌ ៥ អាចចូលមើលតាមរយៈ៖ http://search.wikileaks.org/plusd/cables/07PHNOMPENH103_a.html ["ចំណុចខ្វាស់មួយទៀត គឺផ្តោតលើការជំនុំជម្រះ *ដោយកំបាំងមុខ* ដែលត្រូវបានអនុញ្ញាតតាមច្បាប់កម្ពុជា ប៉ុន្តែមិនត្រូវបានចាត់ទុកថាជាការអនុវត្តអន្តរជាតិដ៏ល្អនោះទេ ។ ចៅក្រមកម្ពុជាបានទទូចថា ការជំនុំជម្រះ *ដោយកំបាំងមុខ* គួរអនុញ្ញាតឱ្យមាននៅក្នុងនីតិវិធី ។ លោក Scheffer បានបញ្ជាក់ថា នៅថ្ងៃទី១៩ ខែមករា ចៅក្រមកម្ពុជា និងអន្តរជាតិ បានឯកភាពគ្នាដូច្នេះថា: ដរាបណាកូនក្តីបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខ អ.វ.ត.ក បន្ទាប់មក មេធាវីការពារក្តីអាចតំណាងកូនក្តីរបស់ខ្លួននៅក្នុងសាលសវនាការ ហើយអាចផ្តល់រូបភាពជាសំឡេង/វីដេអូរ នៅក្នុងបន្ទប់សោតទស្សន៍ដើម្បីតាមដានកិច្ចដំណើរការនីតិវិធី ។ លោក Scheffer បានកត់សម្គាល់ថា ចំណុចខ្វែងយោបល់គ្នាហាក់ដូចជាលែងពាក់ព័ន្ធគ្នាទៀតហើយ"] ។

[75] *សូមមើល កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក ឌុច* ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ E3/915 *កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក នួន ជា* ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ E3/54 និង*កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក អៀង សារី* ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/92 ។ គួរកត់សម្គាល់ថា ក្រុមការពារក្តីរបស់អ្នកស្រី អ៊ឹម ចែម មិនអាចចូលពិនិត្យមើលកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក ខៀវ សំផន និងអ្នកស្រី អៀង ធីរិទ្ធ បានទេ។

៤៣. ហេតុដូច្នេះ នីតិវិធីចោទប្រកាន់នៅ អ.វ.ត.ក ចែងយ៉ាងច្បាស់ថា អ្នកស្រី អ៊ឹម ចែម ត្រូវតែមានវត្តមានក្នុងពេលអ្នកស្រីចូលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីចៅក្រមអាចធ្វើការចោទប្រកាន់លើរូបអ្នកស្រីបាន ។ ចៅក្រម Harmon អាចនឹងងាកទៅប្រើប្រាស់ច្បាប់កម្ពុជាវិញ លុះត្រាតែមានបញ្ហាកើតឡើង ហើយដែលដោយវិធានផ្ទៃក្នុងមិនអាចដោះស្រាយកើត[76] ។ ពិតប្រាកដណាស់ដែលថាវិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យមានការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* នោះទេ ហេតុដូច្នេះ ចៅក្រម Harmon ក៏មិនត្រូវងាកទៅប្រើច្បាប់កម្ពុជាដែរនៅក្នុងបរិបទនេះ ។ បើទោះបីជាចៅក្រម Harmon ត្រូវបានអនុញ្ញាតឲ្យងាកទៅប្រើច្បាប់កម្ពុជាវិញយ៉ាងណាក៏ដោយ ក៏ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ដូចជាទម្លាប់អនុវត្តនៅកម្ពុជា មិនអនុញ្ញាតឲ្យមាននីតិវិធីដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។

### ខ. នីតិវិធីផ្លូវច្បាប់នៅកម្ពុជា ប្រាកដណាស់មិនអនុញ្ញាតឲ្យដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ទេ

#### ក. មាត្រា១៤៣ នៃក្រមនីតិវិធីពហ្មទណ្ឌ តម្រូវឲ្យមានវត្តមានជាក់ស្តែងរបស់បុគ្គលដែលត្រូវធ្វើការចោទប្រកាន់

៤៤. ចៅក្រម Harmon មានកំហុសអង្គច្បាប់ក្នុងការសន្និដ្ឋានថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនមានបទប្បញ្ញត្តិគ្រប់គ្រងលើការដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[77] ។ ច្បាប់នីតិវិធីនៅកម្ពុជា មានបទប្បញ្ញត្តិគ្រប់គ្រងលើដំណើរការចោទប្រកាន់ជនសង្ស័យ ដែលនីតិវិធីច្បាប់នោះតម្រូវយ៉ាងច្បាស់ថា ជនសង្ស័យត្រូវតែមានវត្តមានជាក់ស្តែងនៅពេលចូលបង្ហាញលើកដំបូង។

---

[76] *សូមមើល* បណ្តឹងឧទ្ធរណ៍លើសំណើរបស់លោក នួន ជា សុំមោឃភាព នៅកថាខណ្ឌ១៥ ។ *សូមមើលផងដែរ* សំណុំរឿង០០២ *ដីកាសម្រេចលើសំណើបន្ថែម ស្នើសុំដោះលែងនៅក្រៅឃុំរបស់លោក ខៀវ សំផន* ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ C26/5/5 នៅកថាខណ្ឌ១៧។

[77] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤៣ និង ៤៦។

៤៥. មាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[78] អភិបាលលើកិច្ចដំណើរការចោទប្រកាន់នៅក្នុងច្បាប់កម្ពុជា ។ ក្នុងការសន្និដ្ឋានថាតើការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ*ត្រូវបានអនុញ្ញាតនៅក្រោមច្បាប់កម្ពុជា ឬ យ៉ាងណានោះ ចៅក្រម Harmon ខកខានមិនបានលើកឡើង ឬ ធ្វើការពិចារណាលើមាត្រា១៤៣ បើទោះបីជាមាត្រានេះ ហាមឃាត់យ៉ាងច្បាស់មិនឲ្យធ្វើការចោទប្រកាន់នៅពេលគ្មានវត្តមានរបស់ជនសង្ស័យ។

៤៦. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គួរត្រូវបានបកស្រាយអនុលោមតាមវិធានទូទៅនៃការបកស្រាយវិធានច្បាប់ស៊ីវិល ពីព្រោះក្រមនីតិវិធីនេះ ភាគច្រើនមានមូលដ្ឋានពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង[79] ។ នេះមានន័យថា នៅពេលដែលមានអត្ថបទច្បាប់ច្បាស់លាស់ហើយនោះ បទប្បញ្ញត្តិត្រូវបានបកស្រាយអត្ថន័យតាមន័យត្រង់ (តាមពាក្យពេចន៍ដើមរបស់វា)[80] ។ នៅក្រោមមាត្រា ១៤៣ ចៅក្រមស៊ើបសួរអាចធ្វើការចោទប្រកាន់លើជនសង្ស័យបានតែនៅពេលជននោះបង្ហាញខ្លួនលើកដំបូងតែប៉ុណ្ណោះ ។ ពាក្យខ្មែរសម្រាប់ពាក្យ "appear" ["បង្ហាញ ឬ ធ្វើឲ្យឃើញ"] មានន័យថា ការ "មានវត្តមានជាក់ស្តែង"[81] ។ ស្រដៀងគ្នានឹងវិធាន៥៧ នៃវិធានផ្ទៃក្នុងដែរ នីតិវិធីនៃមាត្រា ១៤៣ កម្រិតថា ជនសង្ស័យតម្រូវឲ្យមានវត្តមាន ពីព្រោះថា ក្នុងអំឡុងពេលចូលបង្ហាញខ្លួនលើក

---

[78] ក្រមនីតិវិធីព្រហ្មណទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") មាត្រា១៤៣.១ ["នៅពេលចូលបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននោះឲ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី ។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

[79] ជើងទំព័រលេខ៤៨ នៃដីកាសម្រេចដែលរងការជំទាស់ ។

[80] *សូមមើលឧទាហរណ៍* ក្នុងការចងក្រងរបស់ C.M. Germain ស្តីពី "យុទ្ធសាស្ត្របកប្រែភាសាតាមច្បាប់ និង ប្រវត្តិនីតិបញ្ញត្តិនៅក្នុងប្រទេសបារាំង លេខ១៣ នៃទិនានុប្បវត្តិនៃការប្រៀបធៀប និងច្បាប់អន្តរជាតិលេខ១៩៥ ដោយ Duke (២០០៣) ទំព័រ ២០១។

[81] វចនានុក្រមពាក្យច្បាប់ អង់គ្លេស-ខ្មែរ ចុះផ្សាយក្នុងឆ្នាំ២០១៣ ទំព័រ៣១ ដែលចងក្រងដោយបណ្ឌិត ឈាង វណ្ណារិទ្ធិ និងសាស្ត្រាចារ្យច្បាប់ អ៊ិន ហ៊ីង ពន្យល់ពីពាក្យខ្មែរ: "ឡើងបង្ហាញខ្លួន ឬ ចូលខ្លួន" មានន័យជាភាសាអង់គ្លេសថា៖ "ចូលខ្លួន" ឬ "ការឡើងបង្ហាញខ្លួន" ឬ ការប្រាកដខ្លួនឡើងដើម្បីបង្ហាញមុខដល់នរណាម្នាក់។

ដំបូង ចៅក្រមស៊ើបសួរត្រូវតែពិនិត្យអត្តសញ្ញាណរបស់ជននោះ ធ្វើការយកចម្លើយភ្លាមៗប្រសិនបើជននោះយល់ព្រម និងយកអសយដ្ឋានរបស់ជននោះ ប្រសិនបើគាត់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីបានបង្ហាញខ្លួនលើកដំបូងហើយ[82] ។ ហេតុដូច្នេះ មាត្រា១៤៣ តម្រូវឱ្យមានវត្តមានរបស់ជនសង្ស័យក្នុងអំឡុងពេលធ្វើការចោទប្រកាន់ មានន័យថា ចៅក្រម Harmon មិនត្រូវដាក់អ្នកស្រី អ៊ឹម ចែម ឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ*បានឡើយ ។

៤៧. មិនមានការពាក់ព័ន្ធគ្នាទេ ចំពោះការដែលចៅក្រម Harmon យោងលើមាត្រា៣៣៣ មាត្រា ៣៥១ មាត្រា៣៦១ និងមាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមាត្រាទាំងនេះ អនុវត្តបានតែនៅក្នុងដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ[83] ។ តាមពិតបទប្បញ្ញត្តិទាំងនេះបង្ហាញថា អ្នករៀបចំសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានបំណងឱ្យមានករណីលើកលែងនូវលក្ខខណ្ឌតម្រូវក្នុងការមានវត្តមានរបស់ជនសង្ស័យនៅពេលចោទប្រកាន់នោះទេ ។ ដូចដែលបានលើកឡើងខាងលើ អ្នកពង្រាងក្រម គួរត្រូវគេសន្មតបានពីការមានចេតនា និង បំណងក្នុងពេលគាត់បញ្ចូលភាសាណាមួយដាក់ទៅក្នុងផ្នែកមួយ ប៉ុន្តែលុបចោលនៅផ្នែកផ្សេងវិញ ។ ម្យ៉ាងវិញទៀត នៅក្នុងច្បាប់ស៊ីវិល ដែលជាច្បាប់មួយអាស្រ័យស្ទើរតែទាំងស្រុងលើវិធានតាមក្រម[84] ជាហេតុធ្វើឱ្យករណីលើកលែងត្រូវតែបានបកស្រាយក្នុងន័យចង្អៀត[85] ។ ខណៈដែលបទប្បញ្ញត្តិទាំងបួននេះ

---

[82] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា១៤៣.១ ។

[83] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤៣ ជើងទំព័របានយោងលើមាត្រា៣៣៣, ដីកាសម្រេចដែលរងការជំទាស់ ជើងទំព័រលេខ៤៥ យោងទៅមាត្រា៣៣៣, ៣៥១, ៣៦១ និង៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[84] *សូមមើលឧទាហរណ៍* នៃដីកាសម្រេចលេខ 2006-540 DC, ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ ក្រុមប្រឹក្សាធម្មនុញ្ញបារាំង « Loi relative au droit d'auteur et aux droits voisins dans la société de l'information (DADVSI) », para. 9 [« Considérant qu'il incombe au législateur d'exercer pleinement la compétence que lui confie la Constitution et, en particulier, son article 34 … [lui impose] d'adopter des dispositions suffisamment précises et des formules non équivoques ; qu'il doit en effet prémunir les sujets de droit contre une interprétation contraire à la Constitution ou contre le risque d'arbitraire, sans reporter sur des autorités administratives ou juridictionnelles le soin de fixer des règles dont la détermination n'a été confiée par la Constitution qu'à la loi »].

[85] *សូមមើលជាទូទៅនៅក្នុងសំណុំរឿងរបស់ Witold Litwa* ទល់នឹងប្រទេស *Poland* (សារណាលេខ: 26629/95) នៅតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ធ្វើឡើងនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០០ កថាខណ្ឌ ៥៩ ស្តីពីការចេញអនុក្រឹត្យផ្តល់សញ្ជាតិដោយទីក្រុង *Tunis* និងទីក្រុង *Morocco (*ក្រុមប្រឹក្សាយោបល់*)*, តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩២៣ ទំព័រ ២៥ ។

ហាក់ជំពាក់ជំពិននឹងករណីលើកលែង ចំពោះលក្ខខណ្ឌតម្រូវឱ្យជនជាប់ចោទត្រូវមានវត្តមាននៅពេលជំនុំជម្រះ ប៉ុន្តែអ្នករៀបចំពង្រាងវិធានផ្ទៃក្នុងមិនបានផ្តល់ការលើកលែងស្រដៀងនេះនៅក្នុងដំណាក់កាលចោទប្រកាន់ឡើយ ។

៤៨. ចៅក្រម Harmon "មិនអាចចូលពិនិត្យមើលឯកសារកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាបានទេ"[86] ហើយគាត់បានត្រឹមតែទាញយកសំអាងលើរឿងក្តីដែលចុះផ្សាយតាមសារព័ត៌មានតែប៉ុណ្ណោះ[87] ។ របាយការណ៍មិនផ្លូវការ គឺមិនអាចជឿទុកចិត្តបានឡើយ ហើយក៏មិនបានបង្ហាញសំអាងហេតុផ្លូវច្បាប់ណាមួយដែរ ។ បើទោះបីជាបទរាយការណ៍ គឺជាអង្គហេតុពិតប្រាកដជាក់ស្តែងក្តី ក៏អង្គហេតុទាំងអស់ដែលបានលើកឡើងសុទ្ធតែពាក់ព័ន្ធជាមួយជនដែលបានរត់គេចខ្លួន ឬ យ៉ាងហោចណាស់ក៏មិនអាចដឹងពីទីតាំងស្នាក់នៅរបស់ជនទាំងនោះដែរ ។ មេដឹកនាំគណបក្សប្រឆាំង លោក សម រង្ស៊ី ត្រូវបានផ្តន្ទាទោស*ដោយកំបាំងមុខ* ដោយសារគាត់រស់នៅប្រទេសបារាំង[88] រីឯជនម្នាក់ដែលត្រូវបានផ្តន្ទាទោសចំពោះការបាញ់បោះលើកម្មកររោងចក្រចំនួនបីនាក់ កំពុងរត់គេចខ្លួននៅឡើយ[89] និងករណីមនុស្សប្រាំមួយនាក់ដែលត្រូវបានផ្តន្ទាទោស*ដោយកំបាំងមុខ* ចំពោះការសម្លាប់អ្នកកាសែតម្នាក់ ក៏មិនដឹងស្ថិតនៅទីកន្លែងណាដែរ ហើយអាជ្ញាធរក៏មិនអាចរកឃើញទីតាំងលាក់ខ្លួនរបស់ពួកគេនៅឡើយទេ[90]។

---

[86] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤៤។

[87] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ៤៤ ត្រង់ជើងទំព័រលេខ៤៧។

[88] "កម្ពុជា: មេដឹកនាំបក្សប្រឆាំងត្រូវបានផ្តន្ទាទោស*ដោយកំបាំងមុខ*" ដោយកាសែត The New York Times, ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ អាចរកបាន:http://www.nytimes.com/2010/09/24/world/asia/24briefs-Cambodia.html?_r=0

[89] អតីតអភិបាលក្រុងបាវិត ត្រូវបានកាត់ទោស*ដោយកំបាំងមុខ* ចំពោះការបាញ់កម្មកររោងចក្រ រាយការណ៍ដោយកាសែត South China Morning Post, ចេញផ្សាយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ អាចរកបាននៅ: http://www.scmp.com/news/asia/article/1268733/ex-cambodian-official-convicted-absentia; 'Cambodian Court Upholds Fugitive Ex-Governor's Conviction', វិទ្យុអាស៊ីសេរី ចេញផ្សាយនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៣ អាចរកបាននៅ: http://www.rfa.org/english/news/cambodia/appeal-11042013143446.html.

[90] បុរសម្នាក់ត្រូវបានចាប់ខ្លួនចំពោះការសម្លាប់អ្នកកាសែតនៅខេត្តកំពង់ឆ្នាំង *កាសែត Cambodia Daily* ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ អាចរកបាននៅ: https://www.cambodiadaily.com/news/one-arrested-for-murder-of-journalist-in-

៤៩. សំណុំរឿងក្តីដែលបានរាយការណ៍នៅក្នុងសារព័ត៌មាន ខុសពីករណីរបស់អ្នកស្រី អ៊ឹម ចែម ។ ទាំងអាជ្ញាធរ និងចៅក្រម Harmon អាច និង រកឃើញទីតាំងស្នាក់នៅរបស់អ្នកស្រី អ៊ឹម ចែម ។ អ្នកស្រី អ៊ឹម ចែម មិនបានលាក់ខ្លួនទេ ហើយមន្ត្រីនគរបាលយុត្តិធម៌ក៏ស្គាល់កន្លែងស្នាក់នៅរបស់អ្នកស្រីដែរ[91] ។ ដូចគ្នានឹងចៅក្រម Harmon ដែរ បុគ្គលិកផ្នែកស៊ើបអង្កេតរបស់គាត់បានប្រគល់ដីកាកោះហៅជូនអ្នកស្រី អ៊ឹម ចែម តាមរយៈអាសយដ្ឋានរបស់អ្នកស្រី[92] ។ បន្ទាប់ពីបានចេញដីកាកោះ និងដីកាបង្គាប់ឱ្យនាំខ្លួនរួចមក ចៅក្រម Harmon ក៏បានចូលរួមកម្មវិធីផ្សព្វផ្សាយមួយនៅអន្លង់វែង ដែលជាភូមិលំនៅរបស់អ្នកស្រី អ៊ឹម ចែម[93] ។

### ខ. ច្បាប់បារាំង ដែលចៅក្រម Harmon បានសំអាងប្រើជាមធ្យោបាយសម្រាប់បកស្រាយច្បាប់កម្ពុជា មិនអនុញ្ញាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ*

៥០. ដើម្បីគាំទ្រជំហររបស់គាត់ ចៅក្រម Harmon ក៏បានសំអាងលើច្បាប់បារាំង តែគាត់បានទាញការសន្និដ្ឋានដោយមិនត្រឹមត្រូវ ដោយថា ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតនៅពេលដែលធាតុពិតនៃច្បាប់នេះមិនអនុញ្ញាតទៅវិញ[94] ។ មូលដ្ឋានរបស់គាត់ក្នុងការទាញសំអាងពីច្បាប់បារាំង គឺថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាភាគច្រើនបានយកពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ហើយអាច "ផ្តល់ជាការណែនាំដោយមានសារប្រយោជន៍" នៅក្នុងការ

---

kompong-chhnang-69988; តុលាការបានសម្រេចផ្តន្ទាទោសលើជនម្នាក់នៅចំពោះមុខ ហើយប្រាំនាក់ផ្សេងទៀត ត្រូវបានធ្វើឡើង *ដោយកំបាំងមុខ* នៅក្នុងសំណុំរឿងសម្លាប់អ្នកកាសែតមួយរូប *The Cambodia Daily* ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ អាចរកបាននៅ: https://www.cambodiadaily.com/news/court-sentences-six-five-in-absentia-for-journalists-murder-72121.

[91] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ៦៧។

[92] ដីកាកោះ ។ កំណត់ហេតុនៃការប្រគល់ដីកាកោះ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ A150/1 ។

[93] *សូមមើល* របាយការណ៍ប្រចាំខែរបស់ អ.វ.ត.ក ចុះក្នុងខែធ្នូ ឆ្នាំ២០១៤ ទំព័រ៣ ។ អាចរកបាននៅ: http://www.eccc.gov.kh/sites/default/files/publications/The%20Court%20Report%20issue%2080%20on%20December%202014.pdf;

[94] ជើងទំព័រលេខ៤៨ នៃដីកាសម្រេចដែលរងការជំទាស់ ។

បកស្រាយបទប្បញ្ញត្តិវិធាននីតិវិធីនៅកម្ពុជា[95] ។ ច្បាប់កម្ពុជាមានប្រភពចេញពីច្បាប់ស៊ីវិល (civil law) របស់បារាំង[96] ហើយចៅក្រម Harmon បានទទួលស្គាល់ដោយខ្លួនគាត់ថា "ទោះបីជាយុត្តិសាស្ត្របារាំងនេះ មិនអាចអនុវត្តផ្ទាល់ ឬ ក៏មិនត្រូវអនុវត្តក៏ដោយ ក៏យុត្តិសាស្ត្រនេះ អាចផ្តល់ការណែនាំដ៏មានប្រយោជន៍នៅក្នុងការបកស្រាយវិធានផ្ទៃក្នុងដែរ[97] ជាពិសេស នៅក្នុងបរិបទនៃការបញ្ជាក់អំពីដំណើរការចោទប្រកាន់។

៥១. ច្បាប់បារាំងក៏បង្ហាញផងដែរថា ជនសង្ស័យត្រូវតែបង្ហាញខ្លួននៅពេលត្រូវធ្វើការចោទប្រកាន់។ មាត្រា៨០-១ មាត្រា៨០-២ និង មាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ជាបទប្បញ្ញត្តិសំខាន់ដែលបានចែងទាក់ទងនឹងដំណើរការចោទប្រកាន់នៅក្នុងតុលាការប្រទេសបារាំង ។ ចៅក្រម Harmon បានភាន់ច្រឡំក្នុងការសំអាងលើមាត្រាទាំងបីនេះ ។ នៅក្រោមច្បាប់នីតិវិធីបារាំង ចៅក្រមស៊ើបសួរអាចចោទប្រកាន់ជនសង្ស័យ តែក្រោយពីការចូលបង្ហាញខ្លួនលើកដំបូងរបស់ជននោះតែប៉ុណ្ណោះ[98] និងបន្ទាប់ពីចៅក្រមបានសួរចម្លើយ ឬ បន្ទាប់ពីបានផ្តល់ឱកាសឲ្យជននោះ

---

[95] ជើងទំព័រលេខ៤៨ នៃដីកាសម្រេចដែលរងការជំទាស់ ។

[96] *សូមមើល* សំណុំរឿង០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកការដាក់សារណារបស់លោក អៀង សារី ឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦ និងការអង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា និងសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី* ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 នៅកថាខណ្ឌ១៧ ។ *សូមមើល* សំណុំរឿង០០២ *ដីកាសម្រេចលើសំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងសារទុក្ខនៅក្នុងសំណុំរឿង០០២/០១* F10/2 ត្រង់កថាខណ្ឌ១៣។

[97] សំណុំរឿង០០៤ *ដីកាសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តីរបស់ តា អាន សុំចូលមើលសំណុំរឿង និង ចូលរួមក្នុងកិច្ចកិច្ចស៊ើបអង្កេត* ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ D121/4 នៅកថាខណ្ឌ៤៤ ។

[98] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១ (១-២) [« Lorsqu'il envisage de mettre en examen une personne qui n'a pas déjà été entendue comme témoin assisté, le juge procède à sa première comparution … Le juge d'instruction constate l'identité de la personne et lui fait connaître expressément, en précisant leur qualification juridique, chacun des faits dont il est saisi et pour lesquels la mise en examen est envisagée »]. *See also*, French Code of Criminal Procedure, Art. 116 al. 5 [« Après avoir, le cas échéant, recueilli les déclarations de la personne ou procédé à son interrogatoire et entendu les observations de son avocat, le juge d'instruction lui notifie … soit qu'elle n'est pas mise en examen … soit qu'elle est mise en examen ; le juge porte alors à la connaissance de la personne les faits ou la qualification juridique des faits qui lui sont reprochés, si ces faits ou ces qualifications diffèrent de ceux qui lui ont déjà été notifiés »]. *See also*, French Code of Criminal Procedure, Art. 80-2 al. 1 [La convocation de la personne qui la reçoit « précise que la mise en examen ne pourra intervenir qu'à l'issue de la première comparution de la personne devant le juge d'instruction »].

ធ្វើសេចក្តីថ្លែងការណ៍ហើយ[99] ។ ការប្រើប្រាស់ឱកាសនេះទៅបាន លុះណាតែជនសង្ស័យចូលបង្ហាញខ្លួនជាក់ស្តែងនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក្រោយពីជនសង្ស័យបានបញ្ចេញយោបល់ (ឬ បានជ្រើសយកជម្រើសនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ) ទើបចៅក្រមស៊ើបសួរអាចធ្វើការសម្រេចចិត្តថា តើត្រូវចោទប្រកាន់ ឬ មិនចោទប្រកាន់លើជនសង្ស័យរូបនោះ[100] ។

៥២. ដូចច្បាប់កម្ពុជាដែរ នីតិវិធី*ដោយកំបាំងមុខ* ពិតជាមានមែននៅក្នុងច្បាប់បារាំង ។ ទោះជាយ៉ាងណាក្តី កាលៈទេសៈកម្រិតដែលត្រូវអនុវត្តនីតិវិធី*ដោយកំបាំងមុខ* មិនពាក់ព័ន្ធទៅនឹងដំណើរចោទប្រកាន់ឡើយ ។ ចៅក្រម Harmon បានយោងលើមាត្រា១៣៤ និងមាត្រា១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[101] និងបានបកស្រាយមាត្រាទាំងពីរនេះខុស ។ មាត្រា១៣៤ ត្រូវតែបានបកស្រាយស្របតាមមាត្រា១៧៦ ហើយបទប្បញ្ញត្តិទាំងពីរនេះ នៅពេលដែលបកស្រាយរួមជាមួយគ្នា ត្រូវអនុវត្តនៅពេលចេញដីកាដំណោះស្រាយ ។ ដីកាបង្គាប់ឲ្យនាំខ្លួន ចេញក្នុងដំណាក់កាលស៊ើបអង្កេត ហើយមិនទទួលបានលទ្ធផលនេះ មិនផ្តល់ឋានៈជា "ជនត្រូវចោទ" ទៅឲ្យជនសង្ស័យទេ រហូតទាល់តែចេញដីកាដំណោះស្រាយ ។ គួរត្រូវអនុវត្តនៅពេលនោះ ពីព្រោះវាជាពេលវេលាដែលចៅក្រមស៊ើបអង្កេត ធ្វើការកំណត់នូវគុណវុឌ្ឍិផ្លូវច្បាប់អំពីបទចោទប្រកាន់នានាក្នុង គោលបំណងដើម្បីបញ្ជូនជននោះទៅជំនុំជម្រះ[102] ។ អាស្រ័យហេតុនេះ មាត្រា១៣៤ មិនអនុវត្តក្នុងអំឡុងពេលស៊ើបសួរទេ ហើយកាន់តែអនុវត្តតិចតួចទៅទៀត នៅពេលដែលការស៊ើបសួរ

---

[99] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៨០ (១-២) [Le juge d'instruction « ne peut procéder à la mise en examen qu'après avoir préalablement entendu les observations de la personne ou l'avoir mise en mesure de les faire, en étant assistée par son avocat, soit dans les conditions prévues par l'article 116 relatif à l'interrogatoire de première comparution » soit en tant que témoin assisté].

[100] French Code of Criminal Procedure, Art. 116 al. 5 [« Après avoir, le cas échéant, recueilli les déclarations de la personne ou procédé à son interrogatoire et entendu les observations de son avocat, le juge d'instruction lui notifie … soit qu'elle n'est pas mise en examen … soit qu'elle est mise en examen »].

[101] ជើងទំព័រលេខ៤៨ នៃដីកាសម្រេចដែលរងការជំទាស់ ។

[102] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា១៣៤.៣ [« Si la personne ne peut être saisie, un procès-verbal de perquisition et de recherches infructueuses est adressé au magistrat qui a délivré le mandat. La personne est alors considérée comme mise en examen pour l'application de l'article 176 »]; and Art. 176 [« Le collège de l'instruction examine s'il existe contre la personne mise en examen des charges constitutives d'infraction, dont il détermine la qualification juridique »]. *See also*, C. Guéry, 'Mandats' in *Répertoire Pénal Dalloz*, ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ១០០ ។

មិនទាន់ត្រូវបានបញ្ចប់ ។

៥៣. ការបកស្រាយនេះ ត្រូវបានគាំទ្រដោយករណីយុត្តិសាស្ត្របារាំង ។ តុលាការកំពូលរបស់បារាំងបានសម្រេចថា ការគ្រាន់តែចេញដីកាបង្គាប់ឱ្យនាំខ្លួនក្នុងអំឡុងពេលស៊ើបសួរ គឺមិនគ្រប់គ្រាន់ដើម្បីចាត់ទុកជនដែលមានឈ្មោះនៅក្នុងដីកានេះថា ជាជនត្រូវចោទនោះទេ[103] ។ តុលាការកំពូលនេះបានផ្តល់សំអាងហេតុបន្ថែមទៀតថា ជនដែលត្រូវនាំខ្លួនដោយដីកាបង្គាប់ឱ្យនាំខ្លួន ប៉ុន្តែមិនបានចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនោះ មិនអាចបំពេញលក្ខខណ្ឌថាត្រូវបានចោទប្រកាន់ឡើយ[104] ។

### គ. វិធានទីតិវិធីអន្តរជាតិ មិនអនុញ្ញាតឱ្យដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ទេ នៅ អ.វ.ត.ក

៥៤. យោងតាមមាត្រា១២ នៃកិច្ចព្រមព្រៀង ចៅក្រម Harmon អាចស្វែងរកការណែនាំនៅកម្រិតអន្តរជាតិបានតែនៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬ នៅពេលមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការអនុវត្តច្បាប់កម្ពុជា ឬ ក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិតែប៉ុណ្ណោះ ។

៥៥. វិធានផ្ទៃក្នុង និងច្បាប់កម្ពុជា និងច្បាប់បារាំង ដែលជាមូលដ្ឋានច្បាប់របស់កម្ពុជាដែរនោះ តម្រូវឱ្យជនសង្ស័យត្រូវមានវត្តមាននៅពេលត្រូវធ្វើការចោទប្រកាន់ ។ គ្មានឡើយភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្តវិធានទាំងនេះ ហើយក៏មិនមានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិដែរ ។ ដូច្នេះ ចៅក្រម Harmon

---

[103] Cass. Crim. 14 May 2002, French *Cour de Cassation*, Bull. Crim. No. 111 [La « délivrance d'un mandat d'arrêt par le juge d'instruction ne confère pas, au cours de l'information, à celui qui en est l'objet, la qualité de personne mise en examen. »].

[104] Cass. Crim. 17 December 2002, French *Cour de Cassation*, Bull. Crim. No. 230 [« Les dispositions des articles 6 et 13 de la Convention Européenne de sauvegarde des Droits de l'Homme ne sont pas applicables en cas de recours formé contre un mandat d'arrêt, dont le seul objet est d'assurer la représentation en justice de la personne à l'encontre de laquelle il est délivré afin, notamment, de permettre son interrogatoire par le juge d'instruction ; en outre … l'intéressé, qui n'a pas comparu devant le juge d'instruction, n'a pas la qualité de personne mise en examen …»].

មិនត្រូវបានអនុញ្ញាតឲ្យស្វែងរកការណែនាំអំពីបញ្ហានេះនៅកម្រិតអន្តរជាតិបានទេ[105] ។

៥៦. ទោះក្នុងករណីណាក៏ដោយ ក៏វិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ មិនបានផ្តល់ការណែនាំអំពីនីតិវិធីដាក់ឲ្យស្ថិតក្រោមការពិនិត្យនៅ អ.វ.ត.ក ដែរ ។ វិធាននីតិវិធីអន្តរជាតិ មិនអនុវត្តនៅក្នុងដំណាក់កាលពិសេសនៃការចោទប្រកាន់ក្នុងករណីនេះឡើយ ឬ សូម្បីតែវាជាទម្រង់ប្លែកគេនៅក្នុងដំណាក់កាលបុរេជំនុំជម្រះនៃតុលាការនេះក្តី ។ ចៅក្រម Harmon មិនបានផ្តល់យុត្តិកម្ម ឬ ក៏ពន្យល់ពីមូលហេតុដែលគាត់ត្រូវបានអនុញ្ញាតឲ្យសម្រាំងយកច្បាប់នីតិវិធីជាក់លាក់ដែលគាត់បានសំអាង ហើយនាំយកនីតិវិធីនោះមកអនុត្តនៅ អ.វ.ត.ក ដោយខុសបរិបទ ។

៥៧. សូម្បីតែសន្មតទុកជាមុនថា ការណែនាំអាចស្វែងរកពីវិធាននីតិវិធីអន្តរជាតិយ៉ាងណាក៏ដោយ ក៏វិធានទាំងនោះ មិនអាចអនុវត្តបានឡើយទៅលើករណីរបស់អ្នកស្រី អ៊ឹម ចែម ។ វិធាននីតិវិធីពីតុលាការអន្តរជាតិផ្សេងទៀត អនុញ្ញាតឲ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* នៅក្នុងកាលៈទេសៈមានដែនកំណត់យ៉ាងតឹងរឹង ហើយករណីរបស់អ្នកស្រី អ៊ឹម ចែម គឺមិនស្ថិតនៅក្នុងកាលៈទេសៈណាមួយក្នុងចំណោមកាលៈទេសៈទាំងនេះទេ ។

### ក. វិធាននីតិវិធីដែលអាចអនុវត្តនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ (“STL”)

៥៨. ដូចដែលវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក “បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯងដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក” ដែរ[106] តុលាការ STL វិញ គឺជាសាលាក្តីកូនកាត់ពិសេសមួយ ដែលអនុវត្តប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដោយពឹងផ្អែកលើច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសរបស់ខ្លួនតែម្តង[107] ។ មិនដូច អ.វ.ត.ក ទេ តុលាការ STL គឺជាតុលាការមួយដែលបាន

[105] *សូមមើល* ដីកាសម្រេចរងការជំទាស់ នៅកថាខណ្ឌ ៤៦។

[106] *សូមមើល* បណ្តឹងឧទ្ធរណ៍លើសំណើរបស់លោក នួន ជា សុំមោឃភាព នៅកថាខណ្ឌ១៤ ។

[107] លក្ខន្តិកៈរបស់តុលាការពិសេសនៃប្រទេសសៀរ៉ាឡេអូន អនុម័តថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មាត្រា២។

បង្កើតឡើងដើម្បីតម្រូវតាមកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ*[108] ។ លិខិតូបករណ៍របស់តុលាការ STL ចែងយ៉ាងច្បាស់ ដោយផ្តល់អំណាចឲ្យចៅក្រមរៀបចំកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ*នៅក្នុងដំណាក់កាលបុរេជំនុំជម្រះ[109] ។ តុលាការ STL ដើរងាកចេញពីសាលាក្តីមុនៗ រាប់បញ្ចូលទាំង អ.វ.ត.ក ផងដែរ ដែលជាតុលាការមិនមានបទប្បញ្ញត្តិស្រដៀងគ្នានេះ[110] ។ ដោយគ្រាន់តែថា សាលាក្តីថ្មីមួយបានបង្កើតដោយមានអំណាចរៀបចំឲ្យមាននូវកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ*នៅដំណាក់កាលបុរេជំនុំជម្រះនោះ ក៏មិនមែនមានន័យថា ចៅក្រម Harmon អាចយកអំណាចបែបនោះមកអនុវត្តនៅ អ.វ.ត.ក នោះទេ ។

៥៩. ទោះបីជាសន្មតទុកជាមុនថា ចៅក្រម Harmon អាចស្វែងរកការណែនាំនៅក្នុងបទប្បញ្ញត្តិស្តីពីនីតិវិធី *ដោយកំបាំងមុខ*របស់តុលាការ STL បានក៏ដោយ ក៏គាត់មិនបានចាត់គ្រប់វិធានការសមហេតុផលទាំងអស់ដែលតម្រូវឲ្យមាន ដើម្បីដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* តាមបទដ្ឋានរបស់តុលាការ STL នោះដែរ ។ តុលាការ STL ដាក់កំហិតលើនីតិវិធី

---

[108] *សូមមើលឧទាហរណ៍* M. Gardner *"ការពិចារណាជាថ្មីចំពោះការជំនុំជម្រះដោយកំបាំងមុខនៅតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន: ការអនុវត្តករណីយុត្តិសាស្ត្រមុនៗរបស់តុលាការនេះ"*។ ទស្សនាវដ្តីច្បាប់អន្តរជាតិរបស់មហាវិទ្យាល័យ George Washington (43 *George Washington International Law Review 91* (2011), នៅទំព័រ 105 ។ M. Wahlisch, "ការណែនាំចំពោះសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសនៃប្រទេសលីបង់ ស្តីពីនីត្យានុកូលភាពរបស់តុលាការពិសេសនៃប្រទេសលីបង់ និងការជំនុំជម្រះ *ដោយកំបាំងមុខ*", ៥២ *International Legal Materials* ១៦៣ (២០១៣), នៅទំព័រ១៦៤ ។

[109] *វិធាននីតិវិធី និងភស្តុតាងនៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន វិធាន១០៥ ស្ទួន និង ៧៦ស្ទួន ។*

[110] *សូមមើលឧទាហរណ៍* M. Gardner *"ការពិចារណាជាថ្មីចំពោះការជំនុំជម្រះដោយកំបាំងមុខនៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន: ការអនុវត្តករណីយុត្តិសាស្ត្រមុនៗរបស់តុលាការនេះ"*។ ទស្សនាវដ្តីច្បាប់អន្តរជាតិរបស់មហាវិទ្យាល័យ George Washington (43 *George Washington International Law Review 91* (2011), នៅទំព័រ 91-91។ C. Aptel "ការបង្កើតថ្មីមួយចំនួននៅក្នុងច្បាប់លក្ខន្តិកៈតុលាការពិសេសនៃប្រទេសសៀរ៉ាឡេអូន" ទស្សនាវដ្តីនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិលេខ៥ ១១០៧ (២០០៧) នៅទំព័រ១១២១ ។ P. Gaeta ('Some innovations in the Statute of the Special Tribunal for Lebanon', 5 *Journal of International Criminal Justice* 1107 (2007)) ។ P. Gaeta "ការជំនុំជម្រះ *ដោយកំបាំងមុខ*នៅតុលាការនៅក្នុងសំណុំរឿងរបស់ Alamuddin និងគូកន, នៅតុលាការពិសេសនៃប្រទេសលីបង់: *Law and practice* (សេចក្តីប្រកាសព័ត៌មានដោសាកលវិទ្យាល័យ Oxford ឆ្នាំ២០១៤) ទំព័រ២៣១។

*ដោយកំបាំងមុខ* នៅត្រឹមស្ថានភាពពិសេសចំនួនបី ដូចមានចែងនៅក្នុងមាត្រា២២(១) នៃលក្ខន្តិកៈរបស់តុលាការនេះ[111] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានកំណត់លក្ខខណ្ឌតម្រូវផ្លូវច្បាប់សំខាន់ៗ ដើម្បីបន្តដំណើរការជំនុំជម្រះ*ដោយកំបាំងមុខ*[112] ហើយទាក់ទងនឹងការជូនដំណឹងអំពីបទចោទប្រកាន់ អង្គជំនុំជម្រះនេះបានបញ្ជាក់នូវចំណុចជាក់លាក់ថា៖

> ខណៈដែលច្បាប់នីតិវិធីរបស់តុលាការនៃប្រទេសលីបង់ តម្រូវឲ្យមានវិធានការផ្លូវការជាក់លាក់មួយចំនួនដើម្បីឈានដល់ 'ការជូនដំណឹង' លក្ខន្តិកៈ និងវិធាន [ស្ដីពីនីតិវិធី និងភស្តុតាង] របស់តុលាការ STL បកស្រាយដោយគិតដល់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងយុត្តិសាស្ត្រពីសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិនានា ក៏តម្រូវឲ្យមានថែមទៀតនូវភស្តុតាងបញ្ជាក់បន្ថែមនៃប្រសិទ្ធភាពនៃការជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅជនជាប់ចោទ"[113] ។

៦០. ដើម្បីសន្និដ្ឋានថា អាជ្ញាធរបានចាត់នូវគ្រប់វិធានការសមហេតុផលទាំងអស់រួចហើយ ដើម្បីធ្វើការជូនដំណឹងជនជាប់ចោទទាំងបួននាក់ នៅក្នុងរឿងក្ដី *Ayyash និងអ្នកផ្សេងទៀត* អំពីបទចោទប្រកាន់ប្រឆាំងពួកគាត់នោះ អង្គជំនុំជម្រះសាលាដំបូងបានត្រួតពិនិត្យច្រើនលើកច្រើនសារ

---

[111] ច្បាប់លក្ខន្តិកៈតុលាការពិសេសនៃប្រទេសសៀរ៉ាឡេអូន មាត្រា២២(១) ចែងៈ "តុលាការពិសេសត្រូវដំណើរការនីតិវិធីជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ ប្រសិនបើគាត់ (ក) បានលះបង់សិទ្ធិរបស់គាត់ដោយចំហ និងជាលាយលក្ខណ៍អក្សរ មិនចូលរួម (ខ) មិនត្រូវបានប្រគល់ខ្លួនមកតុលាការដោយអាជ្ញាពាក់ព័ន្ធរបស់រដ្ឋ (គ) បានរត់គេចខ្លួន ឬ មិនអាចរកឃើញ ហើយបន្ទាប់ពីរាល់ជំហានសមហេតុផលទាំងអស់ត្រូវបានអនុវត្ត ដើម្បីធានាការចូលបង្ហាញខ្លួនរបស់គាត់នៅចំពោះមុខតុលាការ និងដើម្បីប្រាប់គាត់ពីការចោទប្រកាន់ ដែលបញ្ជាក់ដោយចៅក្រមនៃអង្គបុរេជំនុំជម្រះ"។

[112] ករណី*រដ្ឋអាជ្ញា តទល់នឹង* Ayyash *និងគូកន* (STL-11-01/PT/AC/AR126.1), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការពិចារណាសារជាថ្មីនៃដីកាសម្រេចលើការជំនុំជម្រះដោយកំបាំងមុខចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២ ("សាលដីការបស់តុលាការ STL លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ *ដោយកំបាំងមុខ* នៅកថាខណ្ឌ៥០-៥៤។

[113] សាលដីការបស់តុលាការ STL លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ*ដោយកំបាំងមុខ* នៅកថាខណ្ឌ៣៧ ដោយបានសំអាងលើសំណុំរឿង *រដ្ឋអាជ្ញា* តទល់នឹង *Ayyash* និងគូកន (STL-11-01//1/TC), ដីកាសម្រេចលើការជំនុំជម្រះដោយកំបាំងមុខចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ ("ដីកាសម្រេចរបស់តុលាការ STL លើការជំនុំជម្រះ*ដោយកំបាំងមុខ*) នៅកថាខណ្ឌ២៨-៣៩ ។

លើសមត្ថកិច្ចរបស់អាជ្ញាធរលីបង់ដើម្បីស្វែងរកពួកគេ[114] ទោះបីស្ថានភាពសន្តិសុខ និងនយោបាយមានលក្ខណៈរសើបនៅប្រទេសលីបង់ក៏ដោយ[115] ។ ការព្យាយាមស្វែងរករាប់បញ្ចូលទាំងការជូនដំណឹងទៅតាមអាសយដ្ឋានចុងក្រោយបំផុតដែលគេស្គាល់ រួមមានដូចជាៈ អាសយដ្ឋានគ្រួសារ អាសយដ្ឋានកន្លែងការងារ និងការចែកចាយរូបថត និងឈ្មោះរបស់ជនចោទទាំងនេះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន[116] ។ ទោះបីជាមានការព្យាយាមច្រើនលើកច្រើនសាយ៉ាងណាក្តី ក៏គេមិនអាចប្រគល់នូវសេចក្តីជូនដំណឹងនេះទៅដល់ជនត្រូវចោទទាំងបួននាក់នោះដោយផ្ទាល់បានដែរ ។ ហេតុដូច្នេះ កិច្ចដំណើរការនីតិវិធីប្រឆាំងពួកគេ ត្រូវបានធ្វើឡើង*ដោយកំបាំងមុខ* ។

៦១. ចំណាត់ការទាំងនេះ ដែលចៅក្រម Harmon មិនបានយកមកអនុវត្ត គឺបង្ហាញថា គាត់ខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*តាមបទដ្ឋានរបស់តុលាការ STL នោះទេ ។ ចៅក្រម Harmon បានខកខានមិនបានប្រគល់ដោយផ្ទាល់នូវដីកាដែលរងការជំទាស់ ព្រមទាំងការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[117] ទោះបីជាបានដឹងឮពីទីតាំងរបស់អ្នកស្រីហើយក៏ដោយ ។ លើសពីនេះ ចៅក្រម Harmon បានដាក់ឯកសារដែលជាដីកាកំពុងរងការជំទាស់ និង ការជូនដំណឹងពីបទចោទប្រកាន់ ថាជាឯកសារ "សម្ងាត់" ដែលទង្វើនេះ បង្ហាញឲ្យឃើញពីកង្វះនូវចេតនារបស់គាត់មិនចង់ជូនដំណឹងដល់អ្នកស្រី

---

[114] សាលដីការបស់តុលាការ STL លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ*ដោយកំបាំងមុខ* នៅកថាខណ្ឌ៨៣-១០៤ ។

[115] សាលដីការបស់តុលាការ STL លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ*ដោយកំបាំងមុខ* នៅកថាខណ្ឌ ១១៦-១១៧ ។ ក្រុមការពារក្តីបានកត់សម្គាល់ពីការជូនដំណឹងរបស់ចៅក្រម Harmon មានខ្លឹមសារថា "ស្ថានភាពសន្តិសុខនៅលំនៅដ្ឋានរបស់អ្នកស្រី អ៊ឹម ចែម មានបញ្ហា" ។ *សូមមើល* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ២៤ ។

[116] សាលដីការបស់តុលាការ STL លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ*ដោយកំបាំងមុខ* នៅកថាខណ្ឌ ៨៣-១០៤ ។ សាលដីការបស់តុលាការ STL លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការជំនុំជម្រះ*ដោយកំបាំងមុខ* នៅកថាខណ្ឌ៤៤ ។

[117] *សូមមើល* ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ១-៣០។

អ៊ឹម ចែម អំពីបទចោទប្រកាន់ សូម្បីតែធ្វើតាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាន[118] ។ តាមឧទាហរណ៍បន្ថែមទៀត ចំពោះការមិនអនុវត្តឲ្យបាននូវគ្រប់ជំហាននេះ ចៅក្រម Harmon ក៏មិនបានពិនិត្យពិច័យលើជម្រើសក្នុងការចោទប្រកាន់អ្នកស្រី អ៊ឹម ចែម នៅឯភូមិកំណើតរបស់អ្នកស្រី ដូចដែលលោកចៅក្រមបានធ្វើចំពោះលោក អោ អាន នោះទេ ។

## ខ. វិធាននីតិវិធីដែលអាចអនុវត្តនៅតុលាការ ICTY និងតុលាការ ICTR

៦២. អគ្គលេខាធិការអង្គការសហប្រជាប្រជាតិ បានបញ្ជាក់យ៉ាងច្បាស់ថា ការជំនុំជម្រះដោយគ្មានវត្តមានរបស់ជនជាប់ចោទ មិនត្រូវមានចែងនៅក្នុងលក្ខន្តិកៈ ICTY[119] ។ ដូច្នេះ លក្ខន្តិកៈ ICTY និង ICTR មិនអនុញ្ញាតឲ្យមានការជំនុំជម្រះ*ដោយកំបាំងមុខ*ទេ ហើយតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ[120] ។

៦៣. វិធាន ៦១ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់ ICTY និង ICTR មិនគាំទ្រសេចក្ដីសន្និដ្ឋានរបស់ចៅក្រម Harmon ដែលថា "ច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតឲ្យដាក់ជនសង្ស័យ

[118] ចៅក្រម Harmon បានលើកឡើងថា គាត់នឹងចេញសេចក្តីសម្រេចជាសារធារណៈ ដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* នៅក្នុងលិខិតរបស់គាត់ផ្ញើជូនទៅប្រធានគណៈកម្មាធិការសន្តិសុខប្រចាំនៅ អ.វ.ត.ក ។ *សូមមើលលិខិតដាក់ជូនទៅប្រធានគណៈកម្មាធិការសន្តិសុខសប្រចាំ អ.វ.ត.ក* ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ នៅទំព័រ២។

[119] "របាយការណ៍របស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ២ នៃដីកាសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨ (១៩៩៣)", ឯកសាររបស់អង្គការសហប្រជាជាតិ S/25704 ធ្វើនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៣ កថាខណ្ឌ១០១ អាចចូលមើលបាន ៖http://www.icty.org/x/file/Legal%20Library/Statute/statute_re808_1993_en.pdf ["ការធ្វើសវនាការកាត់ទោសលើរឿងក្តីណាមួយ និងមិនអាចចាប់ផ្តើមបានទេរហូតទាល់តែជនជាប់ចោទមានវត្តមាន ដោយផ្ទាល់នៅចំពោះមុខតុលាការអន្តរជាតិ ។ មានការយល់ឃើញជាទូទៅថា ការជំនុំជម្រះ*ដោយកំបាំងមុខ* មិនគួរត្រូវបានចែងក្នុងច្បាប់លក្ខន្តិកៈឡើយ ព្រោះថាវានឹងមិនសមស្របតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ... ដែលបានចែងថា ជនជាប់ចោទត្រូវមានសិទ្ធិទទួលត្រូវបានកាត់ទោសដោយមានវត្តមានរបស់ខ្លួន"] ។

[120] លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ធ្វើវិសោធនកម្មនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩), អនុម័តនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ ("លក្ខន្តិកៈនៃតុលាការ ICTY"), មាត្រា២០ និង មាត្រា២១(៤)(ឃ), លក្ខន្តិកៈនៃតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (ធ្វើវិសោធនកម្មនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១០), អនុម័តនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ("លក្ខន្តិកៈនៃតុលាការ ICTR"), មាត្រា១៩ និង មាត្រា២០(៤)(ឃ) ។

ស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*” [121] ។ វិធាន ៦១ មិនចែងអំពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ឬ ការជំនុំជម្រះ*ដោយកំបាំងមុខ*ទេ[122]។ អង្គចៅក្រមនៅតុលាការ ICTY បានញែកដាច់ពីគ្នាយ៉ាងច្បាស់រវាងវិធាន៦១ និងកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* [123]។ វិធាន ៦១ អនុញ្ញាតឲ្យមានសវនាការដើម្បីស្វែងរកការបញ្ជាក់ឡើងវិញលើដីកាចោទប្រកាន់[124] និងដើម្បីឲ្យចៅក្រមជឿជាក់ថា ជំហានជាបន្តគួរត្រូវបានអនុវត្ត ដើម្បីធានានូវការចូលបង្ហាញខ្លួនរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ ។ ចៅក្រម Harmon ខ្លួនឯង បានបញ្ជាក់អំឡុងពេលដែលគាត់នៅមានងារជាព្រះរាជអាជ្ញារបស់តុលាការ ICTY យ៉ាងដូច្នេះថា៖

លោក Harmon៖...<u>សវនាការតាមវិធាន ៦១ មិនមានចេតនាបង្កើតឲ្យមាននូវការជំនុំ</u>

---

[121] ដីកាសម្រេចដែលរងការចោទប្រកាន់ នៅកថាខណ្ឌ៥៨។

[122] សូមមើលមហាសន្និបាតរបស់អង្គការសហប្រជាជាតិ “របាយការណ៍របស់ក្រុមអ្នកជំនាញដើម្បីពិនិត្យកិច្ចប្រត្តិការ និងការប្រព្រឹត្តដ៏មានប្រសិទ្ធិភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា ឯកសារ A/54/634 ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នៅកថាខណ្ឌ៦០ ។ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ “របាយការណ៍ប្រចាំឆ្នាំលើកទី២របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ការកាត់សេចក្តីលើជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តិឡើងនៅទឹកដីនៃអតីតប្រទេសយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ១៩៩១ ឯកសារ A/50/365-S/1995/728, ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៥ នៅកថាខណ្ឌ១៩៧។

[123] *សូមមើលឧទាហរណ៍ក្នុងសំណុំរឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Rajic* (IT-95-12-R61),*ការពិនិត្យឡើងវិញនៃដីកាចោទប្រកាន់ដោយអនុលោមតាមវិធាន៦១ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង* ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៦ នៅកថាខណ្ឌ៣។ *រឿងក្តីរវាងព្រះរាជអាជ្ញា តទល់នឹង Dragan Nikolic*, (IT-94-2-R61) *ការពិនិត្យឡើងវិញនៃដីកាចោទប្រកាន់ដោយអនុលោមតាមវិធាន ៦១ នៃវិធានស្តីពីភស្តុតាង និង នីតិវិធី* ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៥ នៅកថាខណ្ឌ៣។

[124] *សូមមើលឧទាហរណ៍រឿងក្តីរវាងព្រះរាជអាជ្ញា តទល់នឹង Rajic* (IT-95-12-R61), ដីកាសម្រេចតាមវិធាន៦១ មតិដាច់ដោយឡែករបស់ចៅក្រម Sidhwa ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៦ នៅកថាខណ្ឌ២៧ ថា “ត្រង់ចំណុចដែលត្រូវបានគេកត់សម្គាល់ឃើញថា កិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធាន៦១ ជាកិច្ចដំណើរការនីតិវិធីធ្វើឡើងដោយភាគីតែម្ខាង ។ នីតិវិធីទាំងនេះ គឺគ្រាន់តែមានបំណងដើម្បីស្វែងរកការបញ្ជាក់ឡើងវិញនៃការដីកាបង្គាប់ពីខាងដើមតែប៉ុណ្ណោះ ហើយវានឹងមិនមែនជាកិច្ចដំណើរការនីតិវិធីដោយភាគីតែម្ខាងបានទេ ចំពោះសំណុំបែបបទនៃការកាត់ទោស*ដោយកំបាំងមុខ* លើជនជាប់ចោទណាម្នាក់ ។ ហេតុដូច្នេះ គោលបំណងនៃកិច្ចដំណើរការនីតិវិធីតាមវិធាន៦១ គឺគ្រាន់តែជាការបង្ហាញឡើងវិញពីអត្ថិភាពនៃ*ការមើលឃើញមួយក្រឡេកភ្នែក*ក្នុងការ ប្រឆាំងនឹងជនជាប់ចោទប៉ុណ្ណោះ...។

ជម្រះ*ដោយកំបាំងមុខ* ទេ ។ នេះគឺជាសវនាការដើម្បីបង្គាប់ចិត្តអង្គចៅក្រមឲ្យជឿជាក់ថាមានមូលដ្ឋានសមហេតុផលធ្វើឲ្យជឿជាក់ថា ជនជាប់ចោទទាំងពីរបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬ បទឧក្រិដ្ឋទាំងអស់ក្នុងចំណោមបទឧក្រិដ្ឋផ្សេងទៀត ដូចដែលបានចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយប្រសិនបើការជឿជាក់ត្រូវបានបំពេញហើយនោះ ទើបអាចចាត់នូវវិធានការចាំបាច់ផ្សេងៗដើម្បីធានាថា ទីបំផុត លោកបណ្ឌិត Karadzic និងឧត្តមសេនីយ៍ Mladic ត្រូវបានបង្ហាញខ្លួននៅចំពោះមុខសាលាក្តីនេះ ដូច្នេះ ពួកគាត់ទាំងពីរនឹងអាចត្រូវជំនុំជម្រះពីបទឧក្រិដ្ឋគួរឲ្យខ្លាចដែលពួកគាត់ម្នាក់ៗត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅប្រទេស Bosnia និង Herzegovina [125] (សង្កត់ន័យបន្ថែម)។

៦៤. ដោយចាប់ផ្តើមពីគោលជំហរនេះ ចៅក្រម Harmon មិនអាចយកវិធាន៦១ ដែលជាវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR មកសំអាងដើម្បីដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*បានទេ ។ ចៅក្រម Harmon ប្រើប្រាស់វិធាននេះ មិនមែនដើម្បីស្នើទៅអង្គចៅក្រមឲ្យចាត់វិធានការបន្ថែមទៀតដើម្បីធានាថា អ្នកស្រី អ៊ឹម ចែម បានបង្ហាញខ្លួននៅក្នុងសវនាការទេ ប៉ុន្តែដើម្បីបង្ហាញពីភាពត្រឹមត្រូវក្នុងការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ប្រយោជន៍គឺ "បំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៤ ឲ្យបានចប់សព្វគ្រប់"[126] ដែលទង្វើនេះ ជាមូលដ្ឋានមួយបម្រើឲ្យគោលបំណងផ្សេងមួយទៀតដាច់ដោយឡែកពីគ្នា ។

## គ. វិធាននីតិវិធីដែលអាចអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")

៦៥. ការជំនុំជម្រះ*ដោយកំបាំងមុខ* ត្រូវបានពិភាក្សាអស់រយៈពេលជាយូរនៅក្នុងកំណត់ត្រានាអំឡុង

---

[125] *រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Radovan Karadzić និង Ratko Mladić* (IT-95-18-R61 and IT-95-5-R61 ប្រតិចារិក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៦ នៅទំព័រ៨៩៣។

[126] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៧០។

ពេលដដែកតាក់តែងពីលក្ខន្តិកៈទីក្រុងរ៉ូម[127] ។ លទ្ធផលកើតចេញពីការពិភាក្សាទាំងនោះ ទើបការជំនុំជម្រះបែបនេះត្រូវបានច្រានចោល ហើយមាត្រា៦៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម បញ្ជាក់ថា "ជនជាប់ចោទត្រូវមានវត្តមានក្នុងអំឡុងពេលជំនុំជម្រះ"[128] ។

៦៦. មាត្រា ៦១(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម មិនគាំទ្រសេចក្តីសន្និដ្ឋានរបស់ចៅក្រម Harmon ដែលថា "ច្បាប់អាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតឲ្យដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*"[129] ។ នៅតុលាការ ICC គោលបំណងនៃធ្វើសវនាការដើម្បីបញ្ជាក់ពីបទចោទប្រកាន់ គឺដើម្បីវាយតម្លៃថាតើភស្តុតាងដែលកើតចេញពីការស៊ើបអង្កេត មានលក្ខណៈគ្រប់គ្រាន់ដើម្បីដំណើរការជំនុំជម្រះដែរ ឬ យ៉ាងណា[130] "ដើម្បីញែកករណីដែលនឹងបញ្ជូនទៅជំនុំជម្រះ ចេញពីករណីដែលនឹងមិនបញ្ជូនទៅជំនុំជម្រះ"[131] ។ ក្នុងករណីដែលបទចោទប្រកាន់ត្រូវបានបញ្ជាក់ហើយនោះ អង្គបុរេជំនុំជម្រះពាក់ព័ន្ធ "ធ្វើការកំណត់ពីកម្មវត្ថុជាបញ្ហាចោទនៃរឿងក្តី និងរៀបចំក្របខណ្ឌ

---

[127] *សូមមើលឧទាហរណ៍* "របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីកិច្ចការរបស់សម័យលើកទី៤៥របស់ខ្លួន (ថ្ងៃទី៣ ខែឧសភា-ថ្ងៃទី២៣ កក្កដា ឆ្នាំ១៩៩៣) ឯកសារ A/48/10, ឆ្នាំ១៩៩៣ អាចរកបាននៅ: http://legal.un.org/ilc/documentation/english/A_48_10.pdf, ទំព័រ ១១៩-១២០ "សន្និសិទរបស់អង្គការសហប្រជាជាតិនៃអ្នកការទូតស្តីពីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ (ថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨) ឯកសារ A/CONF.183/13(Vol.III), ឆ្នាំ២០០២, ទំព័រ៥៣-៥៤, ២៩៧-២៩៩, ៣០៣- ៣០៤ ។ អាចរកបាន:
http://legal.un.org/icc/rome/proceedings/E/Rome%20Proceedings_v3_e.pdf,

[128] លក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ("លក្ខន្តិកៈទីក្រុងរ៉ូម) មាត្រា៦៣(១) ។

[129] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៥៨។

[130] *រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង William Samoei Ruto, Henry Kiprono Kosgey,និង Joshua Arap Sang* (ICC-01/09-01/11) *ដីកាសម្រេចលើការបញ្ជាក់នៃការចោទប្រកាន់ស្របតាមមាត្រា៦១(៧)(ក) និង(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម* ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ នៅកថាខណ្ឌ៥១-៥៣។ *រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង Francis Kirimi Muthaura, Uhuru Muigai Kenyatta, និង Mohammed Hussein Ali* (ICC-01/09-02/11) *ដីកាសម្រេចលើការបញ្ជាក់នៃការចោទប្រកាន់ស្របតាមមាត្រា៦១(៧)(ក) និង(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម* ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ នៅកថាខណ្ឌ៦៣-៦៥។

[131] *រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui* (ICC-01/04-01/07) *កំហុសចំពោះដីកាសម្រេចលើទំហំនៃភស្តុតាងនៃសវនាការបញ្ជាក់លើការចោទប្រកាន់, ការទប់ស្កាត់ការវើទីតាំង និងការបញ្ចេញភស្តុតាងនៅក្រោមមាត្រា៦៧(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម និងវិធាន៧៧ នៃវិធាន* ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨ នៅកថាខណ្ឌ៦។

អង្គច្បាប់ និងអង្គហេតុសម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះជាបន្តបន្ទាប់ទៀត"[132] ។ ប្រការនេះ មាត្រា៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម បង្កើតបានជានីតិវិធីផ្ទាល់មាត់ ដែលស្មើនឹងនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះជាលាយលក្ខណ៍អក្សរនៅ អ.វ.ត.ក ហើយមិនផ្តល់ការណែនាំថាតើជនសង្ស័យអាច ឬក៏មិនអាចធ្វើការចោទប្រកាន់ដោយគ្មានវត្តមានរបស់គាត់ សម្រាប់តែគោលបំណងដើម្បីបញ្ចប់កិច្ចការស៊ើបអង្កេតនោះទេ ។

៦៧. បន្ថែមពីលើនេះទៀត ការបញ្ជាក់នូវសវនាការលើបទចោទប្រកាន់ដោយគ្មានវត្តមានរបស់សាមីខ្លួន គឺអនុវត្តក្នុងកាលៈទេសៈលើកលែងតែប៉ុណ្ណោះ[133] ។ ដើម្បីបើកឱ្យមានដំណើរការនីតិវិធីបែបនេះបាន សាមីខ្លួនត្រូវតែបាន៖ ក) លះបង់ចោលនូវសិទ្ធិរបស់ខ្លួនក្នុងការមានវត្តមានក្នុងអំឡុងពេលសវនាការ ឬ ខ) គេចខ្លួន ឬ មិនអាចរកឃើញ[134] ។ ស្ថានភាពទីមួយតម្រូវថា ជននោះត្រូវបានជូនដំណឹងរួចហើយអំពីបទចោទប្រកាន់ប្រឆាំងលើរូបគាត់ ហើយគាត់បានលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលសវនាការបញ្ជាក់ពីបទចោទប្រកាន់[135] ។ នៅក្នុងស្ថានភាពទីពីរ អង្គបុរេជំនុំជម្រះពាក់ព័ន្ធត្រូវតែជឿជាក់ថា រាល់វិធានសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយ ដើម្បីធានាថាជននោះបានបង្ហាញខ្លួន និងដើម្បីជូនដំណឹងគាត់អំពីបទចោទប្រកាន់[136] ។ម្យ៉ាងទៀត ការបើកសវនាការដើម្បីបញ្ជាក់ពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ជានិច្ចកាលតម្រូវថា ជននោះត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ ឬក៏ថា រាល់វិធានការសមហេតុទាំងអស់ត្រូវបាន

---

[132] *រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង* *William Samoei Ruto និងJoshua Arap Sang* (ICC-01/09-01/11), ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញា ស្នើសុំធ្វើវិសោធនកម្មរាល់ឯកសារដែលទើបបានត្រួតពិនិត្យហើយ *ដែលមាននូវបទចោទប្រកាន់មួយចំនួន អនុលោមតាមមាត្រា៦១ (៩) នៃលក្ខន្តិកៈនេះ* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ នៅកថាខណ្ឌ២៥។

[133] *រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo* (ICC-01/04-01/06 OA7) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក* *Thomas Lubanga Dyilo* *ប្រឆាំងនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ១ មានចំណងជើងថា* *"Décision sur la demande de mise en liberté provisoire de Thomas Lubanga Dyilo"*, *មតិដោយឡែករបស់ចៅក្រម* Georghios M. Pikis ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ នៅកថាខណ្ឌ២។

[134] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦១(២) ។

[135] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦០(១) និងមាត្រា ៦១(១), ៦១(២)។

[136] លក្ខន្តិកៈទីក្រុងរ៉ូមមាត្រា៦១(២)(ខ) ។

អនុវត្តរួចហើយ ដើម្បីជូនដំណឹងពីបទចោទនានាមុនពេលមានសវនាការបែបនេះ ។ ដូចបានជំទាស់ពីមុនរួចហើយ ពីការដែលអ្នកស្រី អ៊ឹម ចែម មិនបានគេចខ្លួន ហើយចៅក្រម Harmon ដឹងពីទីកន្លែងដែលអ្នកស្រីរស់នៅ ប៉ុន្តែលោកចៅក្រមបានខកខានមិនបានចាត់វិធានការដើម្បីជូនដំណឹងអ្នកស្រី អ៊ឹម ចែម អំពីបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រីឡើយ ។ ដូច្នេះ ចៅក្រម Harmon មិនបានបំពេញតាមលក្ខខណ្ឌតម្រូវដើម្បីអនុវត្តនីតិវិធី *ដោយកំបាំងមុខ* ដូចមានចែងនៅក្នុងមាត្រា ៦១(២) ទៅលើរឿងក្តីរបស់អ្នកស្រី អ៊ឹម ចែម ទេ។

## ឃ. ការសន្និដ្ឋានលើនីតិវិធីពីសាលាក្តីអន្តរជាតិផ្សេងទៀត

៦៨. ចៅក្រម Harmon បានយកនីតិវិធី *ដោយកំបាំងមុខ* ពីតុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតមកអនុវត្ត ដែលជានីតិវិធីមិនផ្តល់ការណែនាំសម្រាប់នីតិវិធីចោទប្រកាន់របស់ អ.វ.ត.ក ឡើយ ។ នីតិវិធី *ដោយកំបាំងមុខ*របស់តុលាការ STL, ICTY, ICTR និង ICC ត្រូវបានពង្រាងនៅក្នុងបរិបទខុសពី អ.វ.ត.ក និងយោងទៅលើដំណាក់កាលផ្សេងគ្នានៃកិច្ចដំណើរការនីតិវិធី ។ នីតិវិធី *ដោយកំបាំងមុខ* ដែលខុសគ្នាពីសាលាក្តីនីមួយៗ ឆ្លុះបញ្ចាំងឲ្យឃើញថា មិនមានការអនុវត្តដែលគេទទួលយកជាទូទៅទេ ទាក់ទងនឹងការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* នេះ ។ ចៅក្រម Harmon មានកំហុសអង្គច្បាប់ក្នុងការសម្រាំងធាតុផ្សំនៃច្បាប់ខុសៗគ្នាពីសាលាក្តីទាំងឡាយ ដើម្បីលុបចោលលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៥៧ នៃវិធានផ្ទៃក្នុង ដែលតម្រូវថា ជនសង្ស័យត្រូវមានវត្តមាននៅពេលត្រូវធ្វើការចោទប្រកាន់ ។ ជាក់ស្តែង គាត់បានបង្កើតនីតិវិធីថ្មីដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដែលប្រាសចាកយ៉ាងខ្លាំងពីអត្ថន័យធម្មតានៃវិធាន៥៧ ហើយផ្ទុយពីចេតនារបស់អ្នករៀបចំវិធានផ្ទៃក្នុងនេះ ។ ការធ្វើដូច្នេះ បង្កទៅជាការប្រើប្រាស់អំណាចជ្រុលហួសដែនកំណត់ និង រំលោភសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់របស់អ្នកស្រី អ៊ឹម ចែម ។

## ង. ចៅក្រម Harmon បានប្រើប្រាស់អំណាចជ្រុលហួស និងដណ្តើមយកតួនាទីរបស់អង្គជំនុំជម្រះនៃកិច្ចប្រជុំពេញអង្គ តាមរយៈការបង្កើតនីតិវិធីថ្មី គឺការដាក់ឲ្យស្ថិតក្រោមការ

### ពិនិត្យ *ដោយកំបាំងមុខ*

៦៩. ការបង្កើតនីតិវិធីដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដែលមិនមានចែង អ.វ.ត.ក ឬ ក៏នៅក្នុងច្បាប់កម្ពុជានោះ គឺមិនមែនជាការសមស្រប ហើយក៏មិនចាំបាច់ដែរ[137] ។ វិធានផ្ទៃក្នុងគឺមានអត្ថន័យយ៉ាងច្បាស់ហាមឃាត់មិនឲ្យមានការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ ប្រសិនចៅក្រម Harmon បានជឿជាក់ថា *មានចន្លោះប្រហោង*នៅក្នុងវិធានផ្ទៃក្នុងទាក់ទងនឹងការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ហើយបានស្វះស្វែងធ្វើវិសោធនកម្មនៃក្របខណ្ឌច្បាប់ដែលមានស្រាប់នោះ គាត់ត្រូវបានតម្រូវឲ្យដាក់សំណើសុំធ្វើវិសោធនកម្មជូនទៅគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង[138] ។ ដើម្បីបង្កើតអំណាចថ្មីក្នុងការចោទប្រកាន់ មានន័យថា ចៅក្រម Harmon បានដណ្តើមតួនាទីរបស់អង្គជំនុះជម្រះនៃកិច្ចប្រជុំពេញអង្គ[139] ។

៧០. សេចក្តីសន្និដ្ឋានរបស់ចៅក្រម Harmon ដែលថា ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតនៅ អ.វ.ត.ក គឺជាការដើរផ្លូវវាងពីរាល់លក្ខខណ្ឌតម្រូវ និងវិធានការការពារនីតិវិធីទាំងអស់ស្តីពីការបង្កើត និងធ្វើវិសោធនកម្មវិធាននានា ។ ទម្លាប់អនុវត្តនៅ អ.វ.ត.ក គឺថា អង្គភាពតុលាការ រាប់បញ្ចូលទាំងអង្គភាពគាំពារការការពារក្តីផងដែរ ត្រូវតែបានផ្តល់ឱកាសឲ្យដាក់ជាមតិយោបល់ និងសេចក្តីអង្កេតរបស់ខ្លួនលើសំណើសុំធ្វើវិសោធនកម្មវិធានណាមួយ[140]។

---

[137] *សូមមើលសំណុំរឿង០០២ សាលដីកាលើអញ្ញត្រកម្មរបស់ នួន ជា ដែលចោទប្រកាន់ពីចរិតលក្ខណៈអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក* ចុះថ្ងៃទី៨ ខែសីហា ឯកសារ E51/14 នៅកថាខណ្ឌ៧ ។

[138] *សូមមើល* សំណុំរឿង០០២ *សាលដីកាលើសំណើរបស់ក្រុមមេធាវីការពារទាក់ទងនឹងការដាក់សម្ភារៈដើម្បីរៀបចំសម្រាប់ការជំនុំជម្រះ និងអញ្ញត្រកម្ម* ចុះថ្ងៃ៤ ខែមេសា ឆ្នាំ២០១១ E35/2 នៅកថាខណ្ឌ១០ ។ *សូមមើលផងដែរ* វិធាន២, ៣, ២០(២) នៃវិធានផ្ទៃក្នុង។

[139] *សូមមើល* មាត្រា១២(១) នៃកិច្ចព្រមព្រៀង ។ មាត្រា២៣ថ្មី ច្បាប់បង្កើត អ.វ.ត.ក ។ វិធាន២ និងវិធាន២០ នៃវិធានផ្ទៃក្នុង។

[140] ក្រុមការពារក្តីកត់សម្គាល់ឃើញថា មានអនុវត្តបែបនេះមែន ។ ឧទាហរណ៍នៅកិច្ចប្រជុំពេញអង្គលើកចុងក្រោយ និងកិច្ចប្រជុំពេញអង្គលើកទី១១ នៅ អ.វ.ត.ក ដែលពិភាក្សាសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើវិសោធនកម្មលើវិធាន៥៥ និងវិធាន៨៩ស្ទួនពីរ ។ គណៈកម្មាធិការវិធានផ្ទៃក្នុង និងនីតិវិធី បានអញ្ជើញភាគីផ្តល់មតិលើសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ។ *សូមមើល* សារអេឡិចត្រូនិកពីលោក ផន ធឿន មកលោក Isaac Endeley មានចំណងជើងថា

បន្ទាប់មក សំណើសុំធ្វើវិសោធនកម្មនេះ ត្រូវតែពិភាក្សានិងអនុម័តនៅក្នុងសម័យប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញ អនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន១៨ និងដោយគិតទៅលើសេចក្តីសន្និដ្ឋាននានាពីភាគីនីមួយ ដើម្បីឈានដល់ការអនុម័តឲ្យប្រើប្រាស់[141] ។

៧១. ដោយពឹងផ្អែកលើអ្វីដែលបង្ហាញថា *ជាចន្លោះប្រហោង*នៅក្នុងវិធាននានា[142] ចៅក្រម Harmon បានបកស្រាយច្បាប់កម្ពុជា និងច្បាប់បារាំង ព្រមទាំងវិធាននីតិវិធីអន្តរជាតិ ក្នុងកម្រិតមួយដែលគាត់បានបង្កើតនីតិវិធីថ្មី គឺការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ។ ក្នុងការកំណត់នីតិវិធីថ្មីនេះ គាត់បានយកលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់ពីសាលាក្តីផ្សេងៗមកអនុវត្តតាមទំនើងចិត្ត[143]។ លក្ខណៈវិនិច្ឆ័យផ្លូវច្បាប់ ស្តីពីប្រភេទផ្សេងៗនៃនីតិវិធី *ដោយកំបាំងមុខ*ទាំងនោះ គឺមិនទាក់ទងនឹងដំណាក់កាលចោទប្រកាន់ ដូចមានចែងនៅក្នុងនីតិវិធីរបស់ អ.វ.ត.ក ឬ ក៏ទាក់ទងនឹងលក្ខណៈពិសេសរបស់ អ.វ.ត.ក ទាល់តែសោះ ។ ការយកវិធានខាងក្រោមកអនុវត្ត គឺរំលោភសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់របស់អ្នកស្រី អ៊ឹម ចែម ពីព្រោះថា អ្នកស្រីត្រូវតែអាចពឹងផ្អែកលើវិធានរបស់ អ.វ.ត.ក ដែលចែងយ៉ាងច្បាស់ពីការតម្រូវឲ្យមានវត្តមានរបស់ជនសង្ស័យនៅក្នុងអំឡុងពេលចោទប្រកាន់ ។

៧២. ចៅក្រម Harmon មានកំហុសអង្គច្បាប់ក្នុងការសន្និដ្ឋានថា ច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតការដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[144] ហើយការដាក់

---

"សំណើ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ ។ *សូមមើលផងដែរ* សារអេឡិចត្រូនិកពីលោក Lars Olsen ជូនលោក Isaac Endeley មានចំណងជើងថា "ការធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងដែលបានស្នើមកគណៈកម្មាធិការវិធានផ្ទៃក្នុង និងនីតិវិធី" ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ។ ក្រុមការពារក្តីបានដាក់ការអង្កេត ស្តីពីសំណើសុំធ្វើវិសោធនកម្ម ជូនលោក Isaac Endeley ប្រធានអង្គភាពគាំពារការពារក្តី ដែលតំណាងឲ្យក្រុមការពារក្តីទាំងអស់នៅក្នុងកិច្ចប្រជុំពេញអង្គ។

[141] វិធាន១៨(១) នៃវិធានផ្ទៃក្នុង ។

[142] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៤៣។

[143] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៥៨-៦៨។

[144] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៥៨។

អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[145] គឺ *ហួសដែនអំណាច* ។

## VII. សំណើ

តាមសំអាងហេតុទាំងអស់ខាងលើ ក្រុមមេធាវីការពារក្ដី សូមស្នើអង្គបុរេជំនុំជម្រះ ក) ទទួលយកបណ្ដឹងឧទ្ធរណ៍នេះ ខ) ច្រានចោលកថាខណ្ឌ ៣៩,៤០, ៤២-៤៦, ៥៧-៥៨, ៧៣ (ផ្នែកខ្លះ)[146] និងកថាខណ្ឌ ៧៦ ទាក់ទងនឹងការចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម នៅក្នុងដីកាសម្រេចរងការជំទាស់ដែលជាដីកាមានកំហុសអង្គច្បាប់ និង គ) ទុកជាមោឃៈការជូនដំណឹងអំពីបទចោទប្រកាន់ដែល *ហួសដែនអំណាច* ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥

សហមេធាវីការពារក្ដីរបស់អ្នកស្រី អ៊ឹម ចែម

| | |
|---|---|
| ប៊ិត ស៊ាងលឹម | John R.W.D. JONES QC |

[145] ដីកាសម្រេចដែលរងការជំទាស់ នៅកថាខណ្ឌ៧៦ ។ ការជូនដំណឹងអំពីបទចោទប្រកាន់។

[146] ជាពិសេស..."ដោយពិចារណាថា មានភាពមិនច្បាស់លាស់ទាល់តែសោះថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណា ហើយត្រូវអនុវត្ត ឬ អត់នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ការដាក់អ្នកស្រី អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស"។